**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មី

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៤

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ស៊ាង គឹមហុង**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ៅ បុណ្ណា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០

ឆ្នាំសរសេររបាយការណ៍ ២០១៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស៊ាង គឹមហុង** សូមគោរពប្រតិបត្តិ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតរកអ្វីកាត់ថ្លៃពុំបាន ជូនចំពោះអ្នកមានគុណដែលបានផ្តល់កំណើតដល់កូន ថ្នាក់ថ្នម ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូន ដោយលះបង់កំលាំងកាយ កំលាំងចិត្ត ប្រាជ្ញាស្មារតី និងពេលវេលាដ៏មានតម្លៃ ដើម្បីឲ្យកូនរស់យ៉ាងសុខដុមរមនា ពិសេសទៅទៀត លោកទាំងទ្វេបានឲ្យកូនសិក្សារៀនសូត្រ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យ បុគ្គលិក ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកតែងតែជួយជ្រោមជ្រែងបង្ហាត់បង្រៀន អស់ពីកំលាំងកាយ កំលាំងចិត្ត ប្រាជ្ញា ជួយខ្ញុំបាទឲ្យមានលទ្ធភាពក្នុងការបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ។

លោកសាស្ត្រាចារ្យ **ម៉ៅ ម៉ុន្នីណា** ដែលបានណែនាំ និងផ្តល់គំនិតល្អៗដល់ ខ្ញុំបាទក្នុងការធ្វើសារណានេះ។

សូមឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង មន្ត្រីរាជការ សាស្ត្រាចារ្យ ទទួលនូវពរជ័យ សិរីមង្គលវិបុលសុខដ៏បវរមហាប្រសើរ និងទទួលបានពុទ្ធពរ ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ចាប់តាំងពីពេលចូលរៀន និងក្រោយពីបានទទួលការបង្ហាត់បង្រៀន ក្បួនច្បាប់ផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមកិច្ចខិតខំប្រឹងប្រែងយកពេលវេលាដ៏មមាញឹក និងមិនខ្លាចនឿយហត់ពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ បណ្ឌិត អនុបណ្ឌិត និង ឯកឧត្តម លោកជំទាវ នៅតាមក្រសួងស្ថាប័ននានារួចមក និងដើម្បីទទួលបានបរិញ្ញាបត្របញ្ចប់ការសិក្សា ខ្ញុំបាទដែលជានិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំបញ្ចប់ត្រូវបានសាកលវិទ្យាល័យ តម្រូវឲ្យបង្ហាញចំណេះដឹងរបស់ខ្លួនដែល ប្រមូលបានក្នុងរយៈពេលសិក្សា ៤ឆ្នាំកន្លងមកតាមរយៈការសិក្សាដោយផ្ទាល់ជាមួយសាស្ត្រាចារ្យ ដើម្បីប្រមែប្រមូល និងស្រាវជ្រាវរកឯកសារយកមកចងក្រង និងសរសេរជាសារណានេះឡើង។ ម្យ៉ាងវិញទៀត ដើម្បីឆ្លុះបញ្ចាំំឲ្យឃើញពីភាពពិតជាក់ស្តែងក្នុងក្រមព្រហ្មទណ្ឌ ដែលជាច្បាប់ស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ទើបខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយ ដែលមានចំណងជើងថា “**បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មី**”។ បានជាខ្ញុំសម្រេចចិត្តធ្វើការជ្រើសរើសយកប្រធានបទខាងលើនេះ ពីព្រោះថាបទឃាតកម្មនេះពិតជាបានចែងទុកយ៉ាងសំខាន់នៅក្នុងក្រមព្រហ្មទណ្ឌដែលសង្គមខ្មែរមិនអាចខ្វះបាន។ ពិសេសទៅទៀត លទ្ធផលនៃការសរសេរសារណានេះ ជាប្រយោជន៍មួយដើម្បីរួមចំណែកទុកឲ្យប្អូនៗនិស្សិតជំនាន់ក្រោយធ្វើការសិក្សាស្រាវជ្រាវបន្តទៅទៀត។

ខ្ញុំបាទសូមខន្តីអភ័យទោសទុកជាមុននូវរាល់កង្វះខាត ជាពាក្យពេចន៍ក្តី ជាការចងក្រងអត្ថន័យពុំបានស៊ីជម្រៅ និងមិនសូវច្បាស់លាស់ក្តី រួមទាំងកំហុសឆ្គងដោយអចេតនាផ្សេងៗទៀត ដែលខ្ញុំបាទ ពុំបានដឹងជាមុន។

ជាទីបញ្ចប់ ខ្ញុំបាទសង្ឃឹមថាប្រធានបទដែលបានលើកឡើងខាងលើនេះ នឹងបានផ្តល់ជាប្រយោជន៍ដល់និស្សិត និងមិត្តអ្នកអានគ្រប់ៗរូប។

# ឧបសម្ព័ន្ធ

# មាតិកា

ଓଓ📖ଡଡ


**សេចក្ដីថ្លែងអំណរគុណ**

**អារម្ភកថា**

**សេចក្ដីផ្ដើម** ............ ១

**ជំពូកទី ១: បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មី** ............ ៣

**ផ្នែកទី ១. ធាតុផ្សំនៃបទឃាតកម្ម** ............ ៥

១.១.ធាតុផ្សំនីត្យានុកូលនៃបទឃាតកម្ម ............ ៥

១.១.១. ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ............ ៥

១.១.២. ក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆិការ ឆ្នាំ២០០៩ ............ ៦

១.២. ធាតុផ្សំសត្យានុម័តនៃបទឃាតកម្ម ............ ៦

១.២.១. អំពើសម្លាប់មនុស្ស ឬអំពើផ្ដាច់ជីវិតមនុស្ស ឬអំពើប្រល័យជីវិតមនុស្ស ............ ៧

១.២.២. លក្ខណៈសម្បត្តិនៃជនរងគ្រោះ ............ ៧

១.២.២.១. ទារកកើតចេញពីផ្ទៃម្ដាយមកហើយនៅមានជីវិត ............ ៧

១.២.២.២. ជាអ្នកដទៃក្រៅពីជនល្មើសជាដាច់ខាត ............ ៨

១.២.២.៣. ជាមនុស្សដែលរស់រានមានជីវិត ............ ៨

១.៣. ធាតុផ្សំអត្តនោម័តនៃបទឃាតកម្ម ............ ១០

១.៣.១. ចេតនាចង់ផ្ដាច់យកជីវិតរបស់ជនរងគ្រោះ ............ ១១

១.៣.២. មានការយល់ព្រមពីជនរងគ្រោះ ........................................................... ១២

១.៣.៣. ការការពារស្របច្បាប់ ឬការការពារជាធម្មានុរូប ........................................ ១២

**ផ្នែកទី ២. ទោសដែលត្រូវទទួលរងនៃបទឃាតកម្ម** .................................................. ១២

២.១. គ្មានស្ថានទម្ងន់ទោស ........................................................................ ១២

២.២. មានស្ថានទម្ងន់ទោស ......................................................................... ១៣

២.២.១. បទឃាតកម្មគិតទុកជាមុន ................................................................ ១៣

២.២.១.១. គិតទុកជាមុន .............................................................................. ១៣

២.២.១.២. ការពួនស្ទាក់ ............................................................................... ១៤

២.២.២. បទឃាតកម្មដោយការប្រើថ្នាំពុល ......................................................... ១៥

២.២.៣. បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ................ ១៦

២.២.៣.១. បុគ្គលទន់ខ្សោយពិសេសដោយមូលហេតុនៃអាយុ ............................ ១៧

២.២.៣.២. បុគ្គលទន់ខ្សោយពិសេសដោយមូលហេតុនៃជំងឺ ឬពិការភាព ............ ១៧

២.២.៣.៣. បុគ្គលជានារីមានគភ៌ ...................................................................... ១៨

២.២.៣.៤. បុគ្គលជាមន្ត្រីរាជការសាធារណៈ ........................................................ ១៩

២.២.៤. ឃាតកម្មមានស្ថានទម្ងន់ទោសដោយគោលដៅ ....................................... ២១

២.២.៤.១. ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីមិនទាន់ប្ដឹង ............................. ២១

២.២.៤.២. ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី បានប្ដឹងរួច .............................. ២២

២.២.៤.៣. សាក្សីមិនទាន់ផ្ដល់សក្ខីកម្ម ............................................................. ២២

២.២.៤.៤. សាក្សីបានផ្តល់សក្ខីកម្មរួចហើយ ....................................................២៣

២.២.៥. ឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ..........................................២៣

២.២.៥.១. ប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន .................................... ២៤

២.២.៥.២. ប្រព្រឹត្តនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន......................... ២៤

២.២.៦. ឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ ........................................................................................................... ២៥

២.២.៦.១. ឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ .......................... ២៥

២.២.៦.២. ឃាតកម្មដោយមានអំពើរំលោភសេពសន្ថវៈ .................................... ២៥

២.៣. ទោសបន្ថែមនៃបទល្មើសឃាតកម្មៈប្រភេទនិងរយៈពេល..................................... ២៦

**ជំពូកទី ២. ការប្រកាសទោសឃាតកម្ម** .......................................................................... ២៩

**ផ្នែកទី ១. ការប្រកាសទោសឃាតកម្មចំពោះរូបវន្តបុគ្គល** .......................................... ២៩

១.១. ការប្រកាសមូលទោស ......................................................................................... ២៩

១.១.១. ការប្រកាសមូលទោសលើរូបវន្តបុគ្គលជានីតិជន ....................................... ២៩

១.១.២. ការប្រកាសមូលទោសលើរូបវន្តបុគ្គលជាអនីតិជន......................................៣០

១.១.២.១. អនីតិជនមានអាយុក្រោម ១៤ឆ្នាំ........................................................៣០

១.១.២.២. អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ...........................៣០

១.២. ការប្រកាសទោសបន្ថែម.........................................................................................៣២

១.២.១. ការប្រកាសទោសបន្ថែមលើរូបវន្តបុគ្គលជានីតិជន.......................................៣២

១.២.២. ការប្រកាសទោសបន្ថែមលើរូបវន្តបុគ្គលជាអនីតិជន.................................៣២

១.២.២.១. អនីតិជនមានអាយុក្រោម ១៤ឆ្នាំ ....... ៣៣

១.២.២.២. អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ....... ៣៣

១.៣. ការប្រកាសទោសជំនួស ....... ៣៤

១.៣.១. ការប្រកាសទោសការងារសហគមន៍ ....... ៣៤

១.៣.១.១. ការប្រកាសទោសការងារសហគមន៍លើនីតិជន ....... ៣៤

១.៣.១.២. ការប្រកាសទោសការងារសហគមន៍លើអនីតិជន ....... ៣៥

ក. ការប្រកាសទោសការងារសហគមន៍អាយុក្រោម ១៦ឆ្នាំ ....... ៣៥

ខ. ការប្រកាសទោសការងារសហគមន៍អាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ....... ៣៥

១.៣.២. ការប្រកាសទោសស្តីបន្ទោស ....... ៣៦

១.៣.២.១. លក្ខណ្ឌដើម្បីប្រកាសទោសស្តីបន្ទោស ....... ៣៦

១.៣.២.២. ការប្រកាសនូវទោសស្តីបន្ទោសចំពោះរូបវន្តបុគ្គលទាំងពីរភេទ ....... ៣៧

**ផ្នែកទី ២. ការប្រកាសទោសព្រហ្មទណ្ឌចំពោះនីតិបុគ្គល** ....... ៣៧

២.១. នីតិបុគ្គលនៃនីតិសាធារណៈ ឬនីតិបុគ្គលដែលជារដ្ឋ ....... ៣៨

២.២. នីតិបុគ្គលនៃនីតិឯកជន ឬនីតិបុគ្គលមិនមែនជារដ្ឋ ....... ៣៩

**ជំពូកទី ៣: មូលហេតុផ្សេងៗ និងវិធានការប្រឆាំងនឹងអំពើឃាតកម្ម** ....... ៤១

**ផ្នែកទី ១. មូលហេតុមានអំពើឃាតកម្ម** ....... ៤១

១.១. កត្តាក្រៅបុគ្គល ....... ៤១

១.១.១. កត្តាច្បាប់ ........................................................................................ ៤១

១.១.២. កត្តាអប់រំ........................................................................................... ៤២

១.១.៣. កត្តារួមផ្សំផ្សេងៗ .................................................................................. ៤២

១.២. កត្តាបុគ្គល ...........................................................................................................៤៣

**ផ្នែកទី ២. វិធានការប្រឆាំង និងអំពើឃាតកម្ម**........................................................... ៤៤

២.១. វិធានការទប់ស្កាត់.................................................................................................. ៤៤

២.១.១. ពង្រឹងវិស័យច្បាប់ ................................................................................ ៤៥

២.១.២. ពង្រឹងស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ................................................. ៤៥

២.១.៣. បង្កើនការអប់រំតាមបែបសាសនា ប្រពៃណី និងវប្បធម៌............................. ៤៦

២.១.៤. ការបង្កើតមជ្ឈមណ្ឌលអប់រំនានា ..............................................................៤៧

២.១.៥. ស្មេរភាពនយោបាយ ...............................................................................៤៧

២.២. វិធានការបង្ក្រាប ........................................................................................... ៤៨

២.២.១. ពង្រឹងជំនាញដល់អាជ្ញាធរមានសមត្ថកិច្ច................................................... ៤៨

២.២.២. ដាក់ចេញនូវផែនការបង្ក្រាបឲ្យបានម៉ត់ចត់ និងមានប្រសិទ្ធិភាព................ ៤៨

២.២.៣. លើកទឹកចិត្តដល់អាជ្ញាធរដែលសម្រេចបាននូវភារកិច្ច.............................. ៤៩

២.២.៤. ការចូលរួមសហការគ្នារវាងប្រជាពលរដ្ឋ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ......... ៥០

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៥១

**អនុសាសន៍**.................................................................................................................. ៥៤

ឯកសារពិគ្រោះ.................................................................................................... ៥៥
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

កម្ពុជាបច្ចុប្បន្នមានសន្តិភាព ឯកភាពនយោបាយ សង្គមដើរទៅមុខ មានសេដ្ឋកិច្ចរីកចំរើន មានការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងប្រព័ន្ធច្បាប់ជាបន្តបន្ទាប់ រហូតដល់សព្វថ្ងៃនេះយើងសម្រេចបានក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

បើទោះបីជា សង្គមមានការរីកចំរើនយ៉ាងនេះក៏ដោយ ក៏មិនមានន័យថា បទល្មើសមិនបានកើតឡើងនៅក្នុងសង្គមយើងនោះទេ។ ដើម្បីធានាដល់ការរក្សាសណ្តាប់ធ្នាប់សាធារណៈដល់សង្គមជាតិ បទឃាតកម្មត្រូវបានបង្កើតឡើង ដោយមានចែងនៅក្នុងមាត្រា ១៩៩ ដល់ មាត្រា ២០៦ នៃក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩។ ក្នុងការសរសេររបាយការណ៍បណ្ចប់ការសិក្សានេះ គឺខ្ញុំសូមលើកយក (បទឃាតកម្មក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩) មកសិក្សាស្រាវជ្រាវដោយហេតុថា បទល្មើសនេះកំពុងតែកើតឡើងយ៉ាងច្រើននៅក្នុងសង្គមកម្ពុជាយើងបច្ចុប្បន្ន។ ការសិក្សាស្រាវជ្រាវ ទៅលើបទល្មើសនេះ គឺមានន័យថាជាការបង្ហាញឲ្យឃើញពីស្មារតីច្បាប់ដែលបានកំណត់ ថាតើទង្វើបែបណាខ្លះដែលបុគ្គលបានប្រព្រឹត្តហើយត្រូវបានច្បាប់ចែងថាជាបទឃាតកម្ម។ នៅពេលរូបបវន្តបុគ្គល និងនីតិបុគ្គល បានយល់ដឹងអំពីទង្វើដែលច្បាប់ហាមឃាត់ហើយ គេអាចបញ្ចៀសមិនប្រព្រឹត្ត ជាលទ្ធផលធ្វើឲ្យសង្គមយើងមានសុខសន្តិភាពសណ្តាប់ធ្នាប់របៀបរៀបរយបានល្អដើម្បីឆ្ពោះទៅរកនីតិរដ្ឋ។

តើបទឃាតកម្មនៅក្នុងក្រមព្រហ្មទណ្ឌថ្មី ដែលប្រកាសឲ្យប្រើថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មានចរិតលក្ខណៈបែបណាខ្លះ? ហើយមានប៉ុន្មានប្រភេទ?

ប្រធានបទ "បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មី" មានពាក្យគន្លឹះដូចជា បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មី។ ពាក្យថា **បទឃាតកម្ម** សំដៅលើអំពើសម្លាប់មនុស្សដោយចេតនាតាមគ្រប់មធ្យោបាយទោះដោយ ប្រើអាវុធក្តី ឬមិនប្រើអាវុធក្តី។ **ក្រមព្រហ្មទណ្ឌថ្មី** ជាបណ្តុំវិធានកំណត់អំពីបទល្មើសព្រហ្មទណ្ឌដែលទើបតែចូលជាធរមាននៅ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។ បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មី មានន័យថា ជាការកំណត់អំពើសម្លាប់មនុស្សដោយចេតនាតាមគ្រប់មធ្យោបាយដោយប្រើអាវុធក្តី ឬដោយមិនប្រើអាវុធក្តី ដែលមានចែងនៅក្នុងបណ្តុំវិធានដែលកំណត់អំពីបទល្មើសព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ដើម្បីឲ្យខ្លួនខ្ញុំផ្ទាល់ស្វែងយល់ឲ្យកាន់តែច្បាស់អំពី (បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មី) និងចង់បង្ហាញ ឲ្យអ្នកសិក្សាគ្រប់មជ្ឈដ្ឋានស្វែងយល់ឲ្យបានស៊ីជម្រៅទៅលើ ចរិតលក្ខណៈនៃបទល្មើសឃាតកម្មនៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះ។ ជាពិសេស គឺទុកជាឯកសារស្រាវជ្រាវដល់និស្សិតទាំងឡាយដែលមានបំណងស្វែងយល់អំពីបញ្ហានេះ។ យើងសិក្សាតែទៅលើបទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជាយើងតែប៉ុណ្ណោះ ដោយពុំបានធ្វើការសិក្សាទៅលើបទល្មើសផ្សេងដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះឡើយ។ ដើម្បីយល់ឲ្យបានច្បាស់ ខ្ញុំសូមធ្វើការតែងសារណានេះជាពីរជំពូក និងផ្នែក ដូចខាងក្រោមនេះ៖

- **ជំពូកទី ១. បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មី**

    ផ្នែកទី ១. ធាតុផ្សំនៃបទឃាតកម្ម

    ផ្នែកទី ២. ទោសដែលត្រូវទទួលរងនៃបទឃាតកម្ម

- **ជំពូកទី ២. ការប្រកាសទោសឃាតកម្ម**

    ផ្នែកទី ១. ការប្រកាសទោសព្រហ្មទណ្ឌចំពោះរូបវន្តបុគ្គល

    ផ្នែកទី ២. ការប្រកាសទោសព្រហ្មទណ្ឌចំពោះនីតិបុគ្គល

- **ជំពូកទី ៣. មូលហេតុផ្សេងៗនៃអំពីឃាតកម្ម និង វិធានការប្រឆាំងនឹងអំពើឃាតកម្ម**

    ផ្នែកទី ១. កត្តាដែលជាមូលហេតុនាំឲ្យមានអំពើឃាតកម្ម

    ផ្នែកទី ២. វិធានការប្រឆាំង និងអំពើឃាតកម្ម

- **សេចក្តីសន្និដ្ឋាន**
- **អនុសាសន៍**

# ជំពូកទី ១

# បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មី

និយមន័យនៃបទឃាតកម្ម គឺយើងអាចធ្វើការបកស្រាយ ដោយយោងទៅតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩ និងសទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ។

## បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩

បទឃាតកម្ម គឺជាបទល្មើសមួយដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិដាច់ខាតធំបំផុតរបស់មនុស្សគឺ "សិទ្ធិរស់រានមានជីវិត"។ សិទ្ធិជាសារវន្តនេះ មានចែងនិងការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងដោយអត្ថបទអន្តរជាតិដទៃផ្សេងទៀត ជាពិសេស គឺសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ យោងតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន"។ សិទ្ធិរស់រានមានជីវិតនេះ មិនត្រឹមតែបានទទួលស្គាល់ទៅដល់ប្រជាពលរដ្ឋគ្រប់រូបទេ សូម្បីតែឧក្រិដ្ឋជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរក៏ទទួលបាននូវសិទ្ធិនេះដែរ។ ហេតុដូច្នេះហើយ បានជាទោសប្រហារជីវិតនេះត្រូវបានលុបចោលដោយមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ បទឃាតកម្ម ត្រូវបានច្បាប់ចាត់ទុកជាប្រភេទនៃបទឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ។

## សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ

បទឃាតកម្ម គឺជាអំពើសម្លាប់មនុស្សដោយចេតនាតាមគ្រប់មធ្យោបាយ ទោះដោយប្រើអាវុធក្តី ឬមិនប្រើអាវុធក្តី[1]។ ពាក្យថា "សម្លាប់" នេះមានន័យថា ធ្វើឲ្យស្លាប់ (អស់ជីវិត) បំបាត់ជីវិត ឬផ្តាច់ជីវិត[2]។ ដូចនេះ យើងអាចយល់បានថា បទឃាតកម្ម គឺជាអំពើធ្វើឲ្យមនុស្សបាត់បង់ជីវិតដោយចេតនា ឬអំពើផ្តាច់ជីវិតមនុស្សដោយចេតនា ទោះបីជាប្រើអាវុធ ឬមិនប្រើអាវុធក៏ដោយ។

---

[1] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ២០១១ លេខរៀងទី ៦៨

[2] វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ដែលបោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧

ម្យ៉ាងទៀតបទឃាតកម្ម គឺអំពើដែលសម្លាប់ ឬធ្វើឲ្យផ្តាច់ជីវិតរបស់ជនរងគ្រោះ ទោះបីជាធ្វើឡើងដោយមានអាវុធក្តី ឬគ្មានអាវុធក្តី គឺស្តែងចេញតាមគ្រប់រូបភាព និងតាមគ្រប់មធ្យោបាយ។

ឯអ្នកខ្លះគឺប្រព្រឹត្តអំពើដោយដៃទទេ អត់មានប្រើអាវុធទេ និងអ្នកខ្លះប្រើអាវុធ។ តើពាក្យអាវុធសំដៅទៅលើអ្វី? បើយើងពិនិត្យទៅលើក្រមព្រហ្មទណ្ឌ និងឃើញមានចែងនូវពាក្យថាអាវុធដូចខាងក្រោមនេះ៖

"អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើឲ្យមានរបួស។

ត្រូវបានចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀតដែលអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់មនុស្ស នៅក្នុងករណីដូចខាងក្រោម៖

១.វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឲ្យរបួស ឬគំរាមកំហែង។

២.វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឲ្យរបួស ឬគំរាមកំហែង។

ការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឲ្យរបួស ឬគំរាមកំហែង ត្រូវចាត់ទុកដូចបាន ប្រើប្រាស់អាវុធដែរ[3]។"

វត្ថុនៅក្នុងមាត្រានេះ អាចជា វត្ថុរឹង វត្ថុរាវ ឬឧស្ម័ន។ តើអ្វីទៅជាវត្ថុរាវ? គឺមានដូចជាថ្នាំពុល ទឹកអាស៊ីត ឬឧស្ម័នពុល ដូចជាថ្នាំបាញ់មូស យកទៅបាញ់ចូលច្រមុះរហូតទាល់តែពុលស្លាប់។ ទាំងអស់នេះ គឺចូលជាអាវុធដូចគ្នា។ អញ្ចឹងអាវុធនេះគឺទាក់ទងជាមួយនឹង វត្ថុទាំងអស់។ ហើយមួយទៀត គឺសត្វ បើអ្នកដែលប្រើសត្វទៅសម្លាប់ដូចជាបញ្ជាសត្វខ្លា ឬសត្វឆ្កែឲ្យទៅខាំគេរហូតដល់ស្លាប់។

<u>**ចំណាំ**</u> ៖

សូមកុំច្រឡំថាអ្នកដែលបញ្ជាឆ្កែហ្នឹង គឺជាអ្នកផ្តើមគំនិត ទោះបើតាមក្រមនេះគឺមានអ្នកណាដែលបញ្ជា គឺជាអ្នកផ្តើមគំនិត ហើយអ្នកប្រព្រឹត្តដោយផ្ទាល់ គឺចារី។ ស្រាបតែដាក់ថាឆ្កែ គឺជាចារីនៅក្នុងបទឃាតកម្ម ឯមនុស្សជាអ្នកបញ្ជាឆ្កែ គឺជាអ្នកផ្តើមគំនិត នៅក្នុងបទឃាតកម្ម។ នៅក្នុងករណីនេះមិនមែនដូច្នេះទេ បើយោងតាមមាត្រា ៨១ នៃក្រមព្រហ្មទណ្ឌខាងលើ គឺផ្ទុយទៅវិញគឺ៖

---

[3] យោងតាមមាត្រា ៨១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពី អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ

អ្នកដែលបញ្ឆាឆ្កែនៅទីនេះ គឺជាចារី ហើយឆ្កែដែលទៅខាំគេឲ្យស្លាប់ហ្នឹង គឺអាវុធ នេះគឺចូល អំពើឃាតកម្មដោយប្រើអាវុធ។ ខ្លះទៀតគឺធ្វើដោយប្រថ្នាំពុល ឬអំពើឃាតកម្ម មានការពួនស្ទាក់ មានការរៀបចំគម្រោងគិតទុកជាមុន។ ដូច្នេះសកម្មភាពជាសត្យានុម័តនេះ គឺថាអាចធ្វើឡើងដោយ មានការរៀបចំគម្រោងគិតទុកជាមុន ឬក៏មានការពួនស្ទាក់។

## ផ្នែកទី ១. ធាតុផ្សំនៃបទឃាតកម្ម

នៅក្នុងធាតុផ្សំនៃបទល្មើសនេះ យើងនឹងលើកនូវធាតុផ្សំសំខាន់ៗទាំងបីនៃបទល្មើសឃាតកម្ម គឺ **១.១. ធាតុផ្សំនីត្យានុកូលនៃបទឃាតកម្ម, ១.២. ធាតុផ្សំសត្យានុម័តនៃបទឃាតកម្ម** និង **១.៣ ធាតុផ្សំអត្តនោម័តនៃបទឃាតកម្ម** ដែលមានខ្លឹមសារលម្អិតទាំងស្រុងនៅខាងក្រោមនេះ ៖

### ១.១.ធាតុផ្សំនីត្យានុកូលនៃបទឃាតកម្ម

ដើម្បីសិក្សាទៅលើធាតុផ្សំនីត្យានុកូលឲ្យបានច្បាស់លាស់ ខ្ញុំសូមលើកយកពីរចំនុច គឺ **១.១.១. ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល** និង **១.១.២. ក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆិការ ឆ្នាំ២០០៩** មកពិភាក្សា។

#### ១.១.១. ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល

នៅមុនពេលក្រមព្រហ្មទណ្ឌត្រូវបានអនុវត្តទាំងស្រុង បទឃាតកម្ម ឬអំពើមនុស្សឃាតដោយចេតនាត្រូវបានចែងផ្តន្ទាទោសដោយមាត្រា ៣២ ក្នុងមាតិកាទី ៤ ស្តីពីបទឧក្រិដ្ឋ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ដែលមាត្រានេះត្រូវបានកែប្រែដោយច្បាប់ស្តីពី "ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ" ដែលត្រូវបានប្រកាសឲ្យប្រើសដោយ ព្រះរាជក្រមចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២។ មាត្រា ៤ នៃច្បាប់ស្តីពីវិសោធនកម្មក្រោយនេះបានចែងថា "ជនណាដែលបានសម្លាប់មនុស្សដោយចេតនា ឬប៉ុនប៉ងសម្លាប់ជនណាដោយចេតនា ដោយគ្មានស្ថានទម្ងន់ទោសដែលមានចែងក្នុងមាត្រា ៣ ដោយបានប្រើ ឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឲ្យធ្វើការពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ[4]។"

[4] យោងតាមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ឆ្នាំ២០០២ ស្តីពីអំពើមនុស្សឃាតដោយចេតនា

ទាំងអស់ខាងលើ គឺជាធាតុផ្សំនីត្យានុកូល ឬជាធាតុច្បាប់ដែលយើងព្យាយាមបង្ហាញទាំងនៅក្នុងច្បាប់ចាស់ និងក្រមថ្មី។ ក៏ប៉ុន្តែចាប់ពីចំនុចនេះតទៅ ខ្ញុំសុំលើកយកទៅលើក្រមព្រហ្មទណ្ឌថ្មីត្រង់មាត្រា ១៩៩ តែប៉ុណ្ណោះ។

### ១.១.២. ក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆិការ ឆ្នាំ២០០៩

ខាងក្រោមនេះ គឺជាលក្ខខណ្ឌបឋមនៃការកំណត់អំពីបទឃាតកម្មតាមក្រមខ្មែរថ្មី។ ដោយយោងតាមមាត្រា ១៩៩ នៃព្រហ្មទណ្ឌបានចែងថា "អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធ ដោយគ្មានស្ថានទម្រង់ ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) ដល់ មាត្រា២០៥ (បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ) នៃក្រមនេះ គឺជាឃាតកម្ម។ ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ។"

នៅក្នុងក្រមថ្មីយើងនេះ បានប្រើពាក្យថាឃាតកម្ម គឺសំដៅទៅលើអំពើសម្លាប់មនុស្សដោយចេតនា។ ពីមុនយើងមានចែងពី "មនុស្សឃាតដោយចេតនា, ប៉ុនប៉ងសម្លាប់ដោយចេតនា និងឃាតកម្មគិតទុកជាមុន" តែឥឡូវទាក់ទងជាមួយអំពើសម្លាប់មនុស្សដោយចេតនា គឺយើងប្រើពាក្យ "**ឃាតកម្ម**" ទាំងអស់។ អត់មានពាក្យថាឃាតកម្មផ្សេង ឯសម្លាប់មនុស្សផ្សេង ឬក៏មនុស្សឃាតដោយចេតនាផ្សេងនោះទេ គឺអត់មានប្រើពាក្យនេះទៀតទេ តែយើងប្រើពាក្យ ឃាតកម្មហ្នឹង គឺសំដៅទៅលើអំពើសម្លាប់មនុស្សដោយចេតនា។ អន្តន័យរបស់វា គឺអំពើសម្លាប់មនុស្សដោយចេតនាតាមគ្រប់មធ្យោបាយ ទោះបីជាប្រើអាវុធក៏ដោយ មិនប្រើអាវុធ ក៏ដោយឲ្យតែសម្លាប់មនុស្សចេញពីឆន្ទៈរបស់ជនល្មើស គឺគាត់ចង់ផ្តាច់ជីវិតរបស់មនុស្ស វាជាឃាតកម្មទាំងអស់។

### ១.២. ធាតុផ្សំសត្យានុម័តនៃបទឃាតកម្ម

ឥឡូវយើងពិនិត្យមើលអំពីធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈនៃបទល្មើសរបស់វា និងលក្ខខណ្ឌសំខាន់ៗនៃធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈនៅក្នុងបទល្មើសនេះដូចតទៅ៖

### ១.២.១. អំពើសម្លាប់មនុស្ស ឬអំពើផ្ដាច់ជីវិតមនុស្ស ឬអំពើប្រល័យជីវិតមនុស្ស

បទឃាតកម្ម ឬជាបទល្មើសមនុស្សឃាតដោយចេតនា គឺជាប្រភេទបទល្មើសសកម្ម ដូចនេះ អំពើសម្ភារៈនៃបទល្មើសនេះ ត្រូវស្ដែងឡើងក្រោមរូបភាពជាអំពើសម្ភារៈជាវិជ្ជមាន។ និយាយម្យ៉ាងទៀត អំពើសម្លាប់មនស្សនេះត្រូវស្ដែងឡើងជាកាយវិការបង្ហាញមកខាងក្រៅ តាមរយៈអំពើជាសម្ភារៈមួយ ឬ ច្រើន។ អំពើសម្ភារៈនេះ អាចជាអំពើមួយដាច់តែឯង ឬក៏ជាអំពើសម្ភារៈច្រើនរួមគ្នាដែលបណ្ដាលឲ្យជនដទៃស្លាប់ ឬក៏អាចត្រឹមតែបណ្ដាលឲ្យជនដទៃរបួសធ្ងន់ប៉ុណ្ណោះ ព្រោះថាអំពើមនុស្សឃាតដោយចេតនា គឺជាបទឧក្រិដ្ឋដែលការប៉ុនប៉ងប្រព្រឹត្តអំពើនេះ ក៏ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទល្មើសបានសម្រេចដែរ។ អំពើសម្ភារៈនេះ អាចស្ដែងឡើងតាមគ្រប់មធ្យោបាយទាំងអស់ដូចជា ការវាយរហូតដល់ស្លាប់ ការសម្លាប់ដោយបំពុល ដោយការប្រើប្រាស់អាវុធ ដោយការប្រើខ្សែរិតក ដោយឆក់នឹងចរន្តអគ្គិសនី ឬដោយប្រើប្រាស់រថយន្តជាដើម។ ល។ ប៉ុន្តែប្រសិនបើការប្រព្រឹត្តអំពើសម្លាប់មនុស្សដោយចេតនាធ្វើឡើងក្រោមរូបភាពមួយឃោរឃៅ ឬក្រោមរូបភាពជាទារុណកម្មនោះ អំពើទាំងនេះនឹងក្លាយ ទៅជាស្ថានទម្ងន់ទោសនៃអំពើមនុស្សឃាតដោយចេតនាផងដែរ។

### ១.២.២. លក្ខណៈសម្បត្តិនៃជនរងគ្រោះ

ទាក់ទងនឹងជនរងគ្រោះ យើងសាកល្បងបង្ហាញនូវលក្ខណៈសម្បត្តិចំនួន ៣ គឺ៖

- ជនរងគ្រោះត្រូវតែជាទារកើតចេញពីផ្ទៃម្ដាយមកហើយនៅមានជីវិត
- ជនរងគ្រោះត្រូវតែជាអ្នកដទៃយ៉ាងដាច់ខាត និងក្រៅពីជនល្មើស
- ជនរងគ្រោះត្រូវតែជាជនដែលរស់រានមានជីវិត។

#### ១.២.២.១. ទារកកើតចេញពីផ្ទៃម្ដាយមកហើយនៅមានជីវិត

ដើម្បីឲ្យចូលទៅក្នុងធាតុផ្សំនៃអំពើឃាតកម្ម គឺថាត្រូវមានជនរងគ្រោះមានន័យថា ជនរងគ្រោះគឺជាទារកកើតចេញពីផ្ទៃម្ដាយមកហើយមានជីវិត គឺទាល់តែកើតចេញមកក្លាយទៅជាមនុស្សមុនសិនទោះបីជាកើតមកភ្លាមគេហៅគាត់ថាជាទារកក៏ដោយ។

ដូច្នេះទាល់តែការកើតចេញពីផ្ទៃម្ដាយមកហើយ គាត់នៅរស់គឺគាត់មានជីវិតហើយ យើងទៅសម្លាប់ អាហ្នឹងបានប្រព្រឹត្តនូវអំពើឃាតកម្ម ដូចជាពេលកើតមកទារកនោះនៅរស់ តែមានអ្នកទៅ

ច្របាច់កទារកនោះឬទៅជ្រមុចទឹកទារកនោះឲ្យស្លាប់នេះ គឺជាឃាតកម្ម។ អញ្ចឹងលក្ខខណ្ឌទី១ គឺត្រូវមាន ជនរងគ្រោះត្រូវតែជាទារកើតចេញពីផ្ទៃម្ដាយមកហើយនៅមានជីវិត។

<u>**ចំណាំ**</u> ៖

តែបើមិនទាន់ចេញមកពីផ្ទៃម្ដាយផង ដូចជារំលូតទារកក្នុងផ្ទៃ នោះអត់មែនជាអំពើឃាតកម្មទេ។ ចំណុចនេះ គឺយើងត្រូវទៅអនុវត្តតាមច្បាប់ ស្ដីពីការរំលូតកូនវិញ។

### ១.២.២.២. ជាអ្នកដទៃក្រៅពីជនល្មើសជាដាច់ខាត

អ្នកដទៃនៅទីនេះ គឺមិនមែនខ្លួនឯងនោះទេ ប្រសិនបើធ្វើការសម្លាប់ខ្លួនឯង ឬមួយ ធ្វើអត្តឃាតខ្លួនឯង គឺមិនចូលជាបទឃាតកម្មទេ។

<u>**ឧទាហរណ៍**</u> ៖

**ក** យល់ឃើញថាខ្លួនអស់សង្ឃឹមក្នុងជីវិតហើយ មិនដឹងថារស់នៅធ្វើអ្វីទៀតរួចក៏យកថ្នាំពុលមកផឹកសម្លាប់ខ្លួនឯងទៅ។ ដល់ពេលគាត់អស់ស្លាប់ ស្រាប់តែយើងទៅ ចាប់គាត់ដោយចោទពី "បទប៉ុនប៉ងឃាតកម្ម" បើយោងតាមមាត្រាលើនេះ គឺអត់មែនជាបទឃាតកម្មទេពី ព្រោះវាគឺជាជីវិតរបស់ខ្លួនឯង។ ដូច្នេះនៅក្នុងការដែលសម្លាប់ជនរងគ្រោះនេះ គឺទាល់តែជនរងគ្រោះនោះ គឺជាអ្នកដទៃ។ ហើយពាក្យថាជនរងគ្រោះជាអ្នកដទៃហ្នឹងគឺ សំដៅទៅលើអ្នកណាដែលក្រៅពីខ្លួនឯង តែសូមកុំច្រឡំថាក្រៅពីសាច់ញាតិ មិនមែនទេ អ្នកណាក៏ដោយ ជីដូនជីតាក៏ដោយ ឪពុកម្ដាយក៏ដោយ សហព័ន្ធក៏ដោយ កូនចៅក៏ដោយ។ ល។ ឲ្យតែមិនមែនជាខ្លួនឯង ឬក្រៅពីខ្លួនឯង គឺជាអ្នកដទៃទាំងអស់ ហើយដែលនៅក្នុង អត្ថន័យច្បាប់គឺជនរងគ្រោះជាអ្នកដទៃជាដាច់ខាត។ ជាងនេះទៅទៀត ប្រសិនបើជនរងគ្រោះគឺជាកូនចៅ ឪពុកម្ដាយ ឬតាយាយរបស់ជនល្មើស លក្ខណៈសម្បត្តិរបស់ជនរងគ្រោះប្រភេទនេះ គឺជាស្ថានភាពទូទៅ ដែលចៅក្រមតែងតែលើកយកធ្វើការពិចារណាដើម្បី ធ្វើការកំណត់អំពីទណ្ឌកម្មដែលត្រូវផ្ដន្ទាទោសទៅលើជនល្មើសនោះ។

### ១.២.២.៣. ជាមនុស្សដែលរស់រានមានជីវិត

ចុះហេតុដូចម្ដេចបានជា ខ្ញុំលើកពីបញ្ហារស់រានមានជីវិត? ឧបមាថាជាសាកសព ជនម្នាក់ស្លាប់ហើយ ម្យ៉ាងទៀតជនល្មើសដឹងថាស្លាប់ ហើយពោលថា មកមិនទាន់អានេះស្លាប់បាត់ រួចគាត់ក៏ទាញ

កាំភ្លើងទៅដល់បាញ់ជនដែលជាសាកសពនោះចំនួន ២គ្រាប់ទៅ សួរថាតើអំពើដែលគាត់បាញ់សាកសពនេះ ជាអំពើឃាតកម្មដែរឬទេ? ជាចម្លើយគឺអត់ទេ ពីព្រោះឃាតកម្ម ចេតនារបស់ជនល្មើសចង់ផ្តាច់ជីវិតជនរងគ្រោះ ចុះបើជនរងគ្រោះដាច់ជីវិតបាត់ទៅហើយ ឥឡូវទៅធ្វើឃាតកម្មយ៉ាងម៉េចទៀត? តែអំពើនេះគឺចូលបទល្មើស ផ្សេងមួយទៀតគឺ "បទប៉ះពាល់ដល់បូរណភាពសាកសព" ទៅវិញ ពីព្រោះវាទាក់ទងជាមួយនឹង ការគោរពបូជា នឹងជាអំពើមួយដែលប៉ះពាល់ដល់ស្មារតីរបស់ជនទាំងឡាយដែលនៅរស់។ អញ្ចឹងអំពើនេះមិនមែនជាអំពើឃាតកម្មទេ។

ប៉ុន្តែរឿងមួយទៀត ខ្ញុំលើកជាឧទាហរណ៍ថា៖ **ក** ចង់សម្លាប់ **ខ** ហើយគាត់ដឹងថា **ខ** នៅផ្ទះ ថ្ងៃហ្នឹង គាត់ឡើងទៅដល់ក៏បាញ់ **ខ** ប៉ុន្តែ **ខ** មុននឹង **ក** បាញ់ហ្នឹងគឺ **ខ** ដាច់ខ្យល់ស្លាប់ដោយសារខ្យល់គរមុនប្រហែលជា ១ម៉ោងរួចហើយ ប៉ុន្តែ **ក** អត់ដឹងថា **ខ** ស្លាប់ទេ ដោយឡើងទៅដល់ក៏បាញ់ផ្ទូងៗទៅតែ **ខ** ស្លាប់បាត់ទៅហើយ នឹងស្លាប់តាំងពីពេលដែល **ក** ទៅបាញ់នោះទៀត។ សួរថាតើអំពើនេះយ៉ាងម៉េចដែរ? ពីព្រោះក្រោយធ្វើកោសល្យវិច័យឃើញថា ការស្លាប់របស់ **ខ** ហ្នឹងមិនមែនដោយសារតែការបាញ់របស់ **ក** ទេ គឺដោយសារខ្យល់គរ ឬដោយសារស្ថានភាព កាលៈទេសៈផ្សេងទៀត តើអំពើដែល **ក** បាញ់ **ខ** នេះជាអំពើឃាតកម្មដែលឬទេ? ចម្លើយពិតប្រាកដនោះ គឺជាអំពើ "ប៉ុនប៉ងឃាតកម្ម" ព្រោះការប្រព្រឹត្តបទល្មើសរបស់ **ក** មិនបានសម្រេចដោយសារកត្តក្រៅឆន្ទៈផ្សេងទៀតមករាំងមានន័យថា **ក** ទៅសម្លាប់ **ខ** គាត់អត់ដឹងថា **ខ** ស្លាប់ទៅហើយទេ តែបើដឹងថា **ខ** ស្លាប់គាត់នៅតែបាញ់នេះគឺជាអំពើប៉ះពាល់ដល់បូរណភាពសាកសពវិញ ប៉ុន្តែរឿងនេះគឺ **ក** នៅតែគិតថា **ខ** នៅរស់ ដូច្នេះអំពើដែលគាត់បាញ់នេះ គឺជាអំពើឃាតកម្ម នេះគឺអាស្រ័យទៅលើធាតុផ្សំអត្តនោម័ត ឬធាតុចេតនាមួយទៀត។ សួរថា តើគាត់ដឹងទេនៅអំពើរបស់គាត់ថានៅពេលដែលគាត់បាញ់ តើជននោះស្លាប់ហើយឬនៅ? ក្នុងចិត្តគាត់គឺ នៅតែគិតថាជននោះអត់ទាន់ស្លាប់ឬជាជនដែលនៅមានជីវិត។ អញ្ចឹងអំពើនេះនៅតែជាអំពើឃាតកម្មដដែល។

ជនរងគ្រោះអាចជាមនុស្សគ្រប់ប្រភេទ ហើយជនរងគ្រោះអាចមិនត្រូវបានគេស្គាល់ពីអត្តសញ្ញាណ ឬមួយក៏សាកសពរបស់ជនរងគ្រោះអាចមិនត្រូវបានគេរកឃើញ។ ប៉ុន្តែអ្វីដែលសំខាន់ ដើម្បីឲ្យអំពើនោះ ត្រូវបានគេចាត់ទុកថាជាអំពើមនុស្សឃាតដោយចេតនាបាន នោះគឺគេត្រូវបង្ហាញឲ្យឃើញថា ជនរងគ្រោះគឺជាមនុស្សដែលនៅរស់រានមានជីវិតនៅពេលដែលមានអំពើសម្លាប់ ឬប្រល័យជីវិតមនុស្សបានកើតឡើង។ ការផ្តល់សេចក្តីស្លាប់ដល់ជនរងគ្រោះ ទោះបីជាជនរងគ្រោះកំពុងទទួល

រងនូវការឈឺចាប់ ហើយអាចរស់នៅមានជីវិតបាន តែប៉ុន្មាននាទីទៀតក៏ដោយ ក៏គេចាត់ទុកថាអំពើនោះជាអំពើមនុស្សឃាតដោយចេតនាដែលត្រូវផ្តន្ទាទោសផងដែរ។

ដូច្នេះហើយ ពេលខ្លះការតម្រូវឲ្យជនរងគ្រោះមានជីវិតនៅពេលដែលមានអំពើសម្លាប់មនុស្ស គឺពុំមែនជាលក្ខខណ្ឌចាំបាច់ដាច់ខាត ដើម្បីធ្វើការផ្តន្ទាទោសជនល្មើសឡើយ។ ជាគោលការណ៍គេធ្វើការផ្តន្ទាទោសចំពោះអំពើសម្លាប់ ឬប្រល័យជីវិតមនុស្សដែលធ្វើទៅលើសាកសព (ដូចជាការបាញ់ប្រហារទៅលើសាកសព ដោយស្មានថាជាជនដែលនៅរស់រានមានជីវិត) ប៉ុន្តែ ពុំមែនឈរលើមូលដ្ឋាននៃអំពើមនុស្សឃាតចេតនាបានសម្រេចនោះទេ គឺផ្អែកលើមូលដ្ឋាននៃការប៉ុនប៉ងធ្វើមនុស្សឃាតកម្មដោយចេតនាទៅវិញ។ យោងតាមទ្រឹស្តីនេះ គេមិនអាចចាត់ទុកថាមានអំពើមនុស្សឃាតបានសម្រេចកើតនោះទេ ពីព្រោះថា នៅពេលមានអំពើសម្លាប់ ឬប្រល័យជីវិតមនុស្ស ជនរងគ្រោះពុំមែនជាមនុស្សមានជីវិតទេ ប៉ុន្តែជាសាកសពទៅវិញ។ ប៉ុន្តែការស្លាប់មុនអំពើប្រល័យជីវិតមនុស្ស ជាកាលៈទេសៈមួយដែលស្ថិតនៅក្រៅឆន្ទៈរបស់ចារីនៃបទល្មើស ហើយអំពើសម្លាប់ ឬប្រល័យជីវិតមនុស្សនោះ គឺជាអំពើដែលត្រូវបានគេចាត់ទុកថា ជាការចាប់ផ្តើមប្រព្រឹត្តបទល្មើសដែលជាលក្ខខណ្ឌ មួយនាំឲ្យអំពើនោះក្លាយទៅជាអំពើប៉ុនប៉ងដែលត្រូវមានទោស ឬ (បទល្មើសប៉ុនប៉ង)[5] នេះ បើយោងទៅតាមបញ្ញត្តិនៃមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆិការ ឆ្នាំ២០០៩។

<u>កំណត់សម្គាល់</u> ៖

នៅក្នុងធាតុផ្សំសត្យានុម័តនេះ ចំពោះអំពើជាសម្ភារៈ គឺត្រូវមានទំនាក់ទំនងពិតប្រាកដ និងច្បាស់លាស់ជាមួយនឹងមរណភាពរបស់ជនរងគ្រោះ ដែលគេហៅថាទំនាក់ទំនងរវាង ហេតុនិងផលនេះបើយោងតាមទ្រឹស្តីនៃ "នីតិព្រហ្មទណ្ឌទូទៅ"។

### ១.៣. ធាតុផ្សំអត្តនោម័តនៃបទឃាតកម្ម

បើយោងទៅតាមក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ២០០៩ យើងឃើញថាធាតុផ្សំអត្តនោម័តនៃបទឃាតកម្មមានករណីបីជាចំបងគឺ **១.៣.១. ចេតនាចង់ផ្តាច់យកជីវិតរបស់ជនរងគ្រោះ**, **១.៣.២. ការយលព្រមពីជនរងគ្រោះ** និង **១.៣.៣. ការការពារស្របច្បាប់ ឬការការពារជាធម្មានរូប** ៖

[5] យោងតាមមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពី និយម័យនៃការប៉ុនប៉ង

### ១.៣.១. ចេតនាចង់ផ្តាច់យកជីវិតរបស់ជនរងគ្រោះ

ចំពោះធាតុរចេតនានៃអំពើឃាតកម្ម គឺជនល្មើសចង់ផ្តាច់យកជីវិតរបស់ជនរងគ្រោះ មានន័យថា ចង់ឲ្យជនរងគ្រោះស្លាប់បាត់បង់ជីវិតពីលើលោកនេះតែម្តង។ យើងអាចបន្ថែមទៀតថា ធាតុផ្សំអត្តនោម័តនៃអំពើមនុស្សឃាតដោយចេតនា គឺសំដៅលើចេតនារបស់ចារី នៃបទល្មើសក្នុងការផ្តល់សេចក្តីស្លាប់ដល់ជនរងគ្រោះ។ ធាតុចេតនាចេញពី បទល្មើសផ្សេងៗទៀតដែលអាចបណ្តាលឲ្យមានលទ្ធផលដូចគ្នា គឺការបាត់បង់ជីវិតមនុស្ស ដូចគ្នាជាមួយអំពើមនុស្សឃាតដោយអចេតនាជាដើម។ ម្យ៉ាងទៀត ចម្លើយសារភាពរបស់ ចារីដែលជាទូទៅកម្រមាន នេះគឺគ្រាន់តែអាចជាតម្រុយ ក្នុងការកំណត់ចេតនាទុច្ចរិតចង់សម្លាប់ជនរងគ្រោះ។ ដូចនេះជាទូទៅចៅក្រមត្រូវធ្វើសេចក្តីសន្និដ្ឋាននូវធាតុចេតនាទុច្ចរិត នេះដោយធ្វើការពិចារណាទៅលើមូលហេតុនៃការប្រព្រឹត្តរបស់ជនល្មើស ឬធ្វើការវាយតម្លៃទៅលើកាលៈទេសៈផ្សេងៗ ដែលនៅជុំវិញសកម្មភាពល្មើស ឬមរណភាពរបស់ជនរងគ្រោះដូចជា៖

- អាវុធប្រើប្រាស់៖ កាំភ្លើងជាដើម
- ពហុភាពនៃការកាប់ ចាក់ វាយដំ
- ពហុភាពនៃរបួសចំកន្លែងស្លាប់
- មូលហេតុនៃការប្រព្រឹត្តបទល្មើសជាដើម។ ល។

ម្យ៉ាងទៀត ការកំណត់ធាតុចេតនារបស់ជនល្មើសតាមរយៈការសន្មត ឬសច្ចធារណ៍ ទាំងអស់នេះ គឺជាអំណាចឆន្ទានុសិទ្ធិរបស់ចៅក្រមទាំងស្រុង។ ដូចនេះ ចៅក្រមអាចសន្មត ថាមានចេតនាសម្លាប់មនុស្សហើយ នៅពេលដែលចារីនៃបទល្មើស បានដឹងថាអំពើរបស់ ខ្លួននោះនឹងបណ្តាលឲ្យជនរងគ្រោះស្លាប់។ ប៉ុន្តែបញ្ហាអាចចោទឡើងព្រោះថាការសន្មតដូច្នេះអាចនាំឲ្យយើងធ្វើការបែងចែករវាងចេតនា ឬក៏ឆន្ទៈសម្លាប់មនុស្ស និងការដឹងរបស់ជនល្មើសអំពីផលវិបាកនៃអំពើរបស់ខ្លួនថា នឹងបណ្តាលឲ្យមានការបាត់បង់ជីវិតរបស់ជនរងគ្រោះ។ ជាគោលការណ៍ចេតនាសម្លាប់មនុស្ស គឺមិនត្រឹមតែទាញចេញពីឆន្ទៈរបស់ជនល្មើសក្នុងការចង់ទទួលបានលទ្ធផលនៃអំពើរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាញចេញ ពីការដឹងជាមុនរបស់ជនល្មើសអំពីផលវិបាកដែលនឹងកើតឡើងដោយសារអំពើរបស់ខ្លួនទៀតផង។

### ១.៣.២. មានការយល់ព្រមពីជនរងគ្រោះ

ការយល់ព្រមពីជនរងគ្រោះ ពុំមែនជាមូលហេតុនៃការមិនទទួលត្រូវព្រហ្មទណ្ឌនោះឡើយ លើកលែងតែច្បាប់ចែងផ្សេងពីនេះ។ ដូចនេះ វេជ្ជបណ្ឌិតដែលយល់ព្រមចាក់ ថ្នាំសម្លាប់តាមការទទូចស្នើសុំរបស់អ្នកជម្ងឺ ដែលទទួលការឈឺចាប់យ៉ាងខ្លាំងបណ្ដាលមកពីជម្ងឺមហារីករាំរ៉ៃរបស់គាត់ដែលមិនអាចព្យាបាលបាន មិនអាចរួចផុតពីការចោទប្រកាន់ និងផ្ដន្ទាទោសព្រហ្មទណ្ឌពីតុលាការឡើយ ប៉ុន្តែចៅក្រមក៏អាចធ្វើការពិចារណាទៅលើកាលៈទេសៈនេះ ដើម្បីផ្ដល់ការសម្រាលទោសដល់ជនល្មើសបានផងដែរ។ ដូចនេះវាលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ មូលហេតុនៃបទល្មើស គឺពុំអាចលុបចោលនូវចេតនាសម្លាប់មនុស្ស និងអំពើមនុស្សឃាតដោយចេតនាបានឡើយ។

### ១.៣.៣. ការការពារស្របច្បាប់ ឬការការពារជាធម្មានុរូប

ការសម្លាប់មនុស្សដោយការការពារស្របច្បាប់ ឬការការពារជាធម្មានុរូប ដោយមានលក្ខខណ្ឌគ្រប់គ្រាន់តាមការកំណត់របស់ច្បាប់ គឺអាចជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ប៉ុន្តែការភ័ន្តច្រឡំលើជនរងគ្រោះពុំមែនជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ លើកលែងតែការភ័នច្រឡំមួយចំនួនប៉ុណ្ណោះ ដែលអាចនាំឲ្យជនល្មើសរួចផុតពីការចោទប្រកាន់ និងការផ្ដន្ទាទោសពីបទឃាតកម្ម ឬបទមនុស្សឃាតដោយចេតនាដោយជំនួសដោយអំពើមនុស្សឃាតដោយអចេតនាវិញ ដូចជាជនម្នាក់បានបាញ់សំដៅទៅសត្វដោយគិតថាជាសត្វ តែបែរជាទៅបាញ់ត្រូវជនម្នាក់បណ្ដាលឲ្យស្លាប់ទៅ (ចេតនាទុច្ចរិតនៅក្នុងអំពើនេះ គេឲ្យឈ្មោះថា ជាចេតនាទុច្ចរិតជាយថាហេតុនៅក្នុងករណីនេះ ជនល្មើសត្រូវទទួលខុសត្រូវចំពោះកំហុសអចេតនាតែប៉ុណ្ណោះ)។

## ផ្នែកទី ២. ទោសដែលត្រូវទទួលរងនៃបទឃាតកម្ម

ទោលដែលត្រូវទទួលរងនៃបទឃាតកម្ម មានពីរចំនុចធំៗ គឺ **២.១. គ្មានស្ថានទម្ងន់ទោស** និង **២.២. មានស្ថានទម្ងន់ទោស** នៅខាងក្រោមនេះ៖

### ២.១. គ្មានស្ថានទម្ងន់ទោស

សម្រាប់អំពើឃាតកម្មនេះ ប្រសិនគ្មានស្ថានទម្ងន់ណាមួយទេ គឺត្រូវទទួលទោសទៅតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ គឺត្រូវដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ[6]។

### ២.២. មានស្ថានទម្ងន់ទោស

ប្រសិនបើប្រព្រឹត្តបទឃាតកម្មរួចហើយ ថែមទាំងបានបំពេញនូវលក្ខខណ្ឌណាមួយ ដែលមានចែងចាប់ពីមាត្រា ២០០ ដល់ មាត្រា ២០៥ នោះជនល្មើសនឹងត្រូវទទួលនូវស្ថានទម្ងន់ទោសដូចខាងក្រោម៖

#### ២.២.១. បទឃាតកម្មគិតទុកជាមុន

ក្នុងករណីឃាតកម្មធ្វើឡើងដោយមានការគិតទុកជាមុន ឬមានការពួនស្ទាក់ ដូច្នេះឃាតកម្មនេះមានឈ្មោះថា "ឃាតកម្មដោយគិតទុកជាមុន"[7]។ ដោយយោងតាមបញ្ញត្តិមាត្រា ២០០បានចែងថា៖

"ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការពួនស្ទាក់។

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គល នៃជនរងគ្រោះ។

ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្ត អំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។

ឃាតកម្មគិតទុកជាមុន ***ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត***។"

##### ២.២.១.១. គិតទុកជាមុន

ចំពោះ "**ការគិតទុកជាមុន**" នេះ យើងនឹងលើកឧទាហរណ៍មួយវិភាគទាំងអស់គ្នាថាតើគឺ ជាអំពើឃាតកម្មគិតទុកជាមុន ឬក៏មិនមែននោះទេ។

---

[6] យោងតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពី បទឃាតកម្ម

[7] យោងតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីបទឃាតកម្មគិតទុកជាមុន

**ឧទាហរណ៍ ១** ៖ នៅក្នុងស្ថានភាពបច្ចុប្បន្ន អ្នកខ្លះមានគ្រោះថ្នាក់ចរាចរណ៍បន្តិចបន្តួច ពេលចុះពីលើឡានមក មិនជួយដោះស្រាយតាមផ្លូវច្បាប់ បែរទៅជាជជែកយកឈ្នះរៀងខ្លួន ក៏ប៉ះសំដីនិងគ្នារួចវាយគ្នារហូត ដល់មានម្នាក់ស្លាប់។

**ឧទាហរណ៍ ២** ៖ នៅក្នុងករណីមួយទៀតគឺស្រដៀងគ្នាដែរ ពីព្រោះ **ក** និង **ខ** មានគ្រោះថ្នាក់ចរាចរណ៍ រួចឈ្លោះគ្នាតឹងសរសៃក ហើយចង្អុលមុខគ្នាមួយសន្ទុះ ពួកគាត់ក៏ដើរចេញ ទៅបើកឡានរៀងៗខ្លួនបាត់ទៅ។ លុះក្រោយមក **ក** គិតថាតាំងពីកើតមកមិនដែលឃើញ អ្នកណាព្រហើនដូចអាមួយហ្នឹងទេ ហ៊ានមកចង្អុលមុខឯង ហើយគិតថាលែងចង់ឲ្យឃើញមុខវាតទៅទៀតនៅលើផែនដីនេះហើយ ទុកវាឲ្យរស់នៅក្នុងលោកទៀតមិនកើតទេ។ គ្រាន់តែជិះឡានបានប្រហែលជា ៤ ទៅ៥រយម៉ែត្រ ក៏បត់ឡានតាមទៅរក **ខ** វិញដល់ពេលឃើញ **ខ** ក៏ទាញកាំភ្លើងបាញ់ផ្ទងៗរហូតដល់ស្លាប់។

**សំណួរ** ៖ តើឧទាហរណ៍ទី ១ និង ២ មួយណាគឺជា ឃាតកម្មគិតទុកជាមុន?

**ចម្លើយ** ៖ ភាពត្រឹមត្រូវ គឺឧទាហរណ៍ទី ២ ពីព្រោះថាជាឃាតកម្មគិតទុកជាមុនដោយសារតែមានគម្រោង បើទោះបីជាគម្រោងគិតរៀបចំនៅក្នុងការធ្វើអំពើឃាតកម្មនេះរយៈពេលខ្លីឬក៏ រយៈពេលវែងប៉ុណ្ណាក៏ដោយ។ មិនមែនមានន័យថា ទាល់តែមានរៀបចំនូវប្លង់សកម្មភាព ដូចយើងធ្វើគម្រោងការងារនៅតាមស្ថាប័នអីនោះទេ គឺអស់ចាំបាច់ដល់ប៉ុណ្ណឹងទេ គឺឲ្យតែគម្រោងគិតក្នុងចិត្តដើម្បីធ្វើយ៉ាងណាទៅសម្លាប់ជនរងគ្រោះ ឬទៅផ្តាច់យកជីតិជនរងគ្រោះ ទោះបីជារយៈពេលនៃការគិតទុកនេះមានរយៈពេលវែង ឬខ្លីប៉ុនណាក៏ដោយ។

### ២.២.១.២. ការពួនស្ទាក់

ករណីមួយទៀតគឺ "**ការពួនស្ទាក់**" មានន័យថា ទៅឃ្លាំចាំមើលជនរងគ្រោះនៅកន្លែង ណាមួយក្នុងគោលដៅផ្តាច់ជីវិតជនរងគ្រោះ។ បើកាលណាមួយការឃ្លាំចាំ ដើម្បីទៅផ្តាច់ជីវិតជនរងគ្រោះបែបនេះ អំពើដែលធ្វើឡើងទៅលើជនរងគ្រោះនេះគេហៅថា "ឃាតកម្មគិតទុកជាមុន" ទោះបីជាមានការភ័ន្តច្រឡំទៅលើជនរងគ្រោះក៏ដោយ។

**ឧទាហរណ៍** ៖ **ក** បានរង់ចាំដើម្បីសម្លាប់ **ខ** ហើយដឹងថា **ខ** ជារៀងរាល់ថ្ងៃដល់ម៉ោងប៉ុណ្ណឹង គឺដឹងថា **ខ** ដើរមកតាមផ្លូវហ្នឹងហើយ រួចខ្លួនក៏ទៅរង់ចាំនៅផ្លូវហ្នឹងដែរក៏ស្រាប់តែ **ខ** មកដល់ **ក**

បានឃើញក៏ដកកាំភ្លើងបាញ់ ខ រហូតដល់ស្លាប់បាត់ទៅ នេះគឺជាឃាតកម្មគិតទុកជាមុន។ ចុះបើថៃដន្យអីនៅថ្ងៃហ្នឹងស្រាប់តែអ្នកដែលស្លៀកពាក់សំលៀកបំពាក់ និងរាងរ៉ូវគឺវាស្រដៀងនឹង ខ ដែរ តែ ខ អត់បានមកទេ គ្រាន់តែអ្នកផ្សេងដែលស្រដៀងហ្នឹងគាត់ដើរមកតាមផ្លូវហ្នឹងដែរស្រាប់តែ ខ ក៏បាញ់យកតែម្តងដោយគ្មានបានចាំមើលមុខ ខ ឬមិន ខ ទេ ដោយគិតថាអាហ្នឹងហើយសម្បុរហ្នឹងហើយខោអាវហ្នឹងហើយក៏បាញ់ផ្ទងៗស្លាប់ទៅ។

**សំណួរ** ៖ សួរថាតើនេះ គឺជាអំពើឃាតកម្មគិតទុកជាមុនដែរ ឬទេ?

**ចម្លើយ** ៖ នេះគឺនៅតែជាឃាតកម្មគិតទុកជាមុនដដែល ទោះបីជាគោលដៅជនរងគ្រោះនេះច្រឡំក៏ដោយ ពីព្រោះមានការពួនស្ទាក់ជនរងគ្រោះរងចាំជនរងគ្រោះប៉ុន្តែភ័ន្តច្រឡំ។ ការភ័ន្តច្រឡំបែបនេះ គឺគាត់បានគិតថាជនហ្នឹងជាជនរងគ្រោះរួចហើយ ដូច្នេះនៅតែជាឃាតកម្មគិតទុកជាមុនដដែល។ នៅក្នុងអំពើនេះ គឺត្រូវផ្តន្ទាទោសតាមប្បញ្ញត្តិមាត្រា ២០០ គឺដាក់ពន្ធនាគារអស់មួយជីវិត។

### ២.២.២. បទឃាតកម្មដោយការប្រើថ្នាំពុល

នៅក្នុងមាត្រាខាងលើនេះក៏ជាស្ថានទម្ងន់ទោសមួយដែរ ។ បទឃាតកម្មដោយការប្រើថ្នាំពុលគឺជាឃាតកម្មដែលប្រព្រឹត្តដោយការប្រើប្រាស់ថ្នាំពុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ៣០ (សាមសិប)ឆ្នាំ**[8]។

**ឧទាហរណ៍** ៖

មានបុគ្គលពីរនាក់បានឈ្លោះគ្នា ស្រាប់តែម្នាក់បានឃើញថានៅក្បែរហ្នឹង គឺរកអ្វីមិនបានក៏ចាប់បានថ្នាំបាញ់មូសមករួចក៏គៀករជនរងគ្រោះជាប់ ហើយយកថ្នាំនោះមកបាញ់ដាក់ច្រមុះជនរងគ្រោះរហូតដល់ស្លាប់។ នេះគឺជាឃាតកម្មដោយប្រើថ្នាំពុល ពីព្រោះអត់មានបានប្រើមធ្យោបាយអ្វីផ្សេងទៀតទេ គឺយកថ្នាំពុលមកប្រើដើម្បីផ្តាច់ជីវិតជនរងគ្រោះ។

អ្នកខ្លះបានចោទសួរថា តើនេះមិនមែនជាឃាតកម្មគិតទុកជាមុនទេឬ? សូមកុំច្រឡំចំពោះរឿងរៀបចំគម្រោងដើម្បីដាក់ថ្នាំបំពុលជនរងគ្រោះឲ្យស្លាប់នោះទើបយើងហៅថាជា "ឃាតកម្មគិតទុកជាមុន" ចំណែកបញ្ហានេះ អត់បានរៀបគម្រោងឡើយ។ ឧបមាថាមកដល់ គាត់អត់បានគិត និងរៀប

[8] យោងតាមមាត្រា ២០១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពី បទឃាតកម្មដោយប្រើថ្នាំពុល

គម្រោងក្នុងការសម្លាប់ជនហ្នឹងពីមុនទេ ស្រាប់តែថ្ងៃហ្នឹងក៏មានរឿងទាស់ទែងគ្នា ហើយឃើញថ្នាំពុលនៅក្បែរហ្នឹង ក៏ស្ទុះទៅទាញថ្នាំពុលនោះយកមកធ្វើ ជាមធ្យោបាយដើម្បីសម្លាប់ជនរងគ្រោះ។ បទល្មើសប្រភេទបែបនេះគឺច្បាប់កំណត់ទុកជាស្ថានទម្ងន់ទោស។ ហើយសូមកុំច្រឡំ ប្រយ័ត្នទៅទាញយកមាត្រា ២០១ យកទៅប្រើចំពោះ អ្នកដែលរៀបចំគម្រោងដាក់ថ្នាំពុលឲ្យគេស្លាប់នោះថាចូលក្នុងមាត្រានេះហើយ។

**ឧទាហរណ៍ ៖**

**ក** មានគុំនុំគុំគួនជាមួយ **ខ** រួចក៏ចង់សម្លាប់។ **ក** ក៏បានអញ្ជើញ **ខ** ឲ្យទៅញុំាបាយជាមួយខ្លួន។ ពេលទៅដល់គាត់បានរៀបគម្រោងដាក់ថ្នាំពុលនៅក្នុងបាយដើម្បីឲ្យ **ខ** បានហូបបាយនោះទៅត្រូវស្លាប់ហើយ។

សួរថាតើអំពើនេះត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ ឬមាត្រា ២០១? គឺតាមមាត្រា ២០០ ពីព្រោះវានៅតែគិតទុកជាមុនដដែល។ កុំច្រឡំថាជាឃាតកម្មដោយការប្រើថ្នាំពុល ដោយភ្លេចគិតទៅដល់ថាមានរៀបចំគម្រោងទុកជាមុនឲ្យសោះ។

ការប្រើថ្នាំពុលនៅទីនេះ គឺចង់បញ្ជាក់ថាយកថ្នាំពុលធ្វើជាមធ្យោបាយក្នុងការធ្វើឃាតកម្មដែលមិនចូលធាតុផ្សំជាឃាតកម្មគិតទុកជាមុន គឺអត់មានបានរៀបចំគម្រោងអីមុននោះទេ។ ចំពោះឃាតកម្មដោយប្រើថ្នាំពុលនេះគឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬដាក់គុក ពី **១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ៣០ (សាបសិប)ឆ្នាំ**។

## ២.២.៣. បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

មាត្រាមួយនេះ គឺជាឃាតកម្មទៅលើជនរងគ្រោះមួយចំនួនដែលច្បាប់កំណត់ថាត្រូវ ទទួលស្ថានទម្ងន់ទោស នៅក្នុងបញ្ញត្តិមាត្រា ២០២ បានចែងអំពីជនរងគ្រោះទាំងនោះថា៖

"ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ៣០ (សាមសិប)ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ៖

1.បុគ្គលដែលទន់ខ្សោយពិសេសដោយមូលហេតុអាយុនៃបុគ្គលនោះ។

2.បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

3.នារីមានគភ៌ កាលបើគភ៌ត្រូវបានឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

4.អ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន[9]។"

### ២.២.៣.១. បុគ្គលទន់ខ្សោយពិសេសដោយមូលហេតុនៃអាយុ

ការធ្វើឃាតកម្មទៅលើមនុស្សដែលក្មេងពេក ហើយខ្វះលទ្ធភាពទប់ទល់ និងការពារខ្លួន ឬក៏អ្នកដែលមានវ័យចាស់ពេក បើមើលទៅវ័យគាត់ខ្សោយទៅហើយដោយដើរទ្រេតទ្រូតៗ ពីព្រោះមានអាយុ ៨០-៩០ឆ្នាំ ទៅហើយ គ្រាន់តែថាក្មេងរត់មកប៉ះក៏ដួលដែរ ទាំងនេះគឺជាឃាតកម្មទៅលើបុគ្គលដែលទន់ខ្សោយពិសេសដោយមូលហេតុនៃអាយុ។

អញ្ចឹងយើងត្រូវពិនិត្យមើល ស្ថានភាពថាតើជននេះទន់ខ្សោយដែរឬក៏អត់ បើមានអាយុប៉ុណ្ណឹង? បើសិនជាមានអាយុប៉ុណ្ណឹង គាត់មានស្ថានភាពទន់ខ្សោយទៅហើយនោះគឺ ការចោទប្រកាន់ដើម្បីផ្តន្ទាទោសត្រូវធ្វើទៅតាមបញ្ញត្តិមាត្រា ២០២ ចំណុចទី ១។ ដូចជាករណីប្រព្រឹត្តទៅលើក្មេងអាយុ ៤-៥ឆ្នាំ ជាដើមនោះគឺ ១០០% ដែលហៅថាទន់ខ្សោយ តិចទៅថាក្មេងហ្នឹងឃើញម៉ាប់ៗវាខ្លាំងដែរ អត់មែនទន់ខ្សោយទេ គឺមិនមែនអញ្ចឹងឡើយ ពីព្រោះឃាតកម្មទៅលើក្មេងអាយុ ៣ ទៅ១០ឆ្នាំចុះមកក្រោមនេះ គឺទន់ខ្សោយហើយ។ ចុះបើវា មានអាយុ ១៦-១៧ឆ្នាំវិញ តើអាចទន់ខ្សោយដែរឬទេ? គឺអាចដែរក្នុងករណីដូចជាមនុស្ស ដែលបាក់ទឹកដោះតាំងពីក្មេងមករហូតធ្វើឲ្យស្គមស្គាំងតែល្វៃៗ ដើរញ៉ើរញ៉័រៗ ដូច្នេះមនុស្ស ប្រភេទនេះហើយគឺជាមនុស្សទន់ខ្សោយពិសេសហើយ។

### ២.២.៣.២. បុគ្គលទន់ខ្សោយពិសេសដោយមូលហេតុនៃជំងឺ ឬពិការភាព

មនុស្សដែលទន់ខ្សោយពិសេសដោយសារតែមូលហេតុមានជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។ សួរថាតើជម្ងឺដល់កម្រិតណាដែលធ្វើឲ្យគាត់ទន់ខ្សោយ? ឬពិការបៀបណា ដែលធ្វើឲ្យគាត់ទន់ខ្សោយ? មិនមែនគ្រាន់តែក្អកផ្តាសាយ ហើយមានឃាតកម្មទៅលើគាត់ គឺចូលក្នុងចំណុចទី ៣ នេះទេ ឬគិតថាជាស្ថានភាពទន់ខ្សោយ

[9] យោងតាមមាត្រា ២០២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីបទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

ហើយគឺត្រូវប្រើមាត្រា ២០២ នោះឡើយ។ ក៏ប៉ុន្តែប្រសិនបើគាត់ឈឺធ្ងន់ធ្ងរមែនទែនហើយរហូតដល់ ដើបពីគ្រែមិនចង់រួច ដើររញើររញ៉ូវៗទៅហើយ ប្រសិនបើមានឃាតកម្មទៅលើបុគ្គលប្រភេទនេះ គឺចូលទៅក្នុងប្បញ្ញត្តិមាត្រា ២០២ ដែលជាមូលហេតុនៃស្ថានទម្ងន់។ ដូច្នេះសូមញែកឲ្យច្បាស់ប្រយ័ត្ន យល់ច្រឡំថាឲ្យតែមានជម្ងឺគឺចូលទៅក្នុងស្ថានទម្ងន់ទាំងអស់ គឺអត់មែនអញ្ចឹងទេ។ ឬមួយវិញទៀតគឺ ពិការភាព ចំពោះពាក្យថាពិការភាពនេះក៏ត្រូវពិនិត្យទៅតាមស្ថានភាពមួយៗដែរ។ មិនមែនពិការភាព គ្រាន់តែកុតស្លឹកត្រចៀកមួយចំហៀងទេ ពីព្រោះបើនិយាយពីពិការភាព ជនប្រភេទនេះគឺពិការភាព ហើយ ក៏ប៉ុន្តែសួរថាតើកម្រិតត្រឹមតែប៉ុណ្ណឹងទន់ខ្សោយឬក៏អត់? គឺអត់មែននោះទេ មានអ្វីដែលត្រូវទន់ខ្សោយត្រឹមប៉ុណ្ណឹងៗ ហើយមានអ្វីដែលត្រូវថមថយ នូវលទ្ធភាពទប់ទល់របស់គាត់។ ចុះបើកុតដៃកុត ជើង គឺចូលទៅក្នុងចំណុចទី ៣នេះហើយបើគាត់ពិការដៃម្ខាង និងមិនសូវមានកម្លាំង ក៏អាចចូលក្នុង រឿងយើងដែរ ដោយសារតែគាត់ថមថយកម្លាំងដែរហើយ ពីព្រោះមិនដូចអ្នកមានដៃពីរនោះទេ។ ផ្ទុយ ទៅវិញ បើគាត់ពិការដៃម្ខាងតែគាត់ពូកែវៃគ្នាយ៉ាងខ្លាំង ដូច្នេះក៏អាចឈ្នះគេដែរ។ ដោយមូលហេតុនេះ ហើយ ទើបគេឲ្យពិចារណាថា តើគាត់ទន់ខ្សោយដោយមូលហេតុពិការភាពដែរ ឬអត់? គេឲ្យយកពាក្យ ពីរហ្នឹងមកបញ្ចូលគ្នាគឺ ទន់ខ្សោយពិសេស និងដោយមូលហេតុតែចំណុចសំខាន់ជាងគេគឺពាក្យថា "ទន់ខ្សោយ"។ តើទន់ខ្សោយដោយសារអ្វី? ដោយមូលហេតុពិការភាព។ ហេតុនេះបើពិការដៃម្ខាង ប៉ុន្តែ គាត់នៅមានកម្លាំងខ្លាំងក្លា ឬរឹងមាំ បើមានអ្នកដៃពីរចំនួន ៣នាក់ ចូលមកសាកវៃគ្នាជាមួយគាត់ លមើល ម្យ៉ាងទៀតគាត់គឺជា ម្ចាស់ខ្សែក្រវាត់ខ្មៅការ៉ាត់តេដូប៉ុន្មានដាន់ផង កុំឲ្យតែកាំភ្លើង គឺទប់ទល់ ជាមួយគាត់មិនបានទេ ដូច្នេះគេត្រូវពិនិត្យមើលផងដែរនៅក្នុងអត្ថន័យនេះ ពីព្រោះធាតុរបស់វាសំខាន់ គឺទន់ខ្សោយ ពិសេស ដោយមូលហេតុជម្ងឺ ឬក៏ពិការភាព ហេតុនេះទាល់តែចូលទៅក្នុងស្ថានភាពហ្នឹង ផ្ទុយទៅវិញ បើអត់ទន់ខ្សោយទេគឺមិនយកចំណុចទី ៣នៃមាត្រា ២០២ នេះមកប្រើទេ។

**ចំណាំ** ៖ មាត្រានេះគឺមិនយកមូលហេតុស្រវឹងស្រា ឬញៀនគ្រឿងញៀន ថាចាត់ចូលទៅជា មូលហេតុទន់ខ្សោយពិសេសនោះឡើយ។ ដូច្នេះច្បាប់មិនលើកលែងករណីនេះទេ។

### ២.២.៣.៣. បុគ្គលជានារីមានគភ៌

រាល់ការប្រព្រឹត្តបទល្មើសទៅលើនារីដែលមានគតិ ដូច្នេះឃាតកម្មចំពោះនារីមានគតិ ក៏ច្បាប់ កំណត់ចូលទៅក្នុងស្ថានទម្ងន់ទោសផងដែរ។ បើសិនជាគតិនោះមើលឃើញយជាក់ស្តែង គឺចូលទៅ ក្នុងចំណុចនេះហើយ។ ករណីមួយទៀត គឺជនល្មើសដឹងថានាងមានគតិ ហើយនៅតែធ្វើឃាតកម្មទៅ

លើនាងទៀត នោះនឹងចូលទៅក្នុងស្ថានទម្ងន់ តាមប្បញ្ញត្តិនៃមាត្រា ២០២ ចំណុចទី២នេះដែរ។ នេះគឺយើងនិយាយអំពីឃាតកម្មដោយគ្មានការគិតទុកជាមុនទេ ដែលត្រូវទទួលស្ថានទម្ងន់បែបនេះ។ តើបើសិនជាគិតទុកជាមុនគឺចូលទៅក្នុងមាត្រា ២០០ទាំងអស់។

ចំណាំ ៖ សូមកុំច្រឡំថាប្រព្រឹត្តទៅលើនារីមានគត៌ និងមានការគិតទុកជាមុនបែរជាទៅយកមាត្រា២០២មកប្រើវិញ គឺខុសនឹងស្មារតីនៃក្រមនេះហើយ។ ចំពោះបញ្ហានៃការគិតទុកជាមុន ទោះបីជាបុគ្គលប្រភេទហ្នឹងជាមនុស្សទន់ខ្សោយក៏ដោយ ជានារីមានគតិក៏ដោយ គឺត្រូវប្រើមាត្រា ២០០ ទាំងអស់ ឲ្យតែមានការគិតទុកជាមុន។ ផ្ទុយទៅវិញប្រសិនបើអត់មានការគិតទុកជាមុនទេ តែប្រព្រឹត្តទៅលើប្រភេទបុគ្គលបែបនេះ គឺត្រូវទទួលស្ថានទម្ងន់តាមបញ្ញត្តិមាត្រា ២០២។

### ២.២.៣.៤. បុគ្គលជាមន្ត្រីរាជការសាធារណៈ

រាល់ការប្រព្រឹត្តទៅលើអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។ តើអ្នកណាគឺជាអ្នករាជការសាធារណៈ? អត្ថន័យលម្អិតគឺមាននៅក្នុងប្បញ្ញត្តិមាត្រា ៣០ នៃក្រមនេះ ដែលបានឲ្យអត្ថន័យនៃអ្នករាជការសាធារណៈច្បាស់ណាស់ និងរួមបញ្ចូលទាំងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតផងដែរ ទាំងអស់នេះគឺសុទ្ធតែជាអ្នករាជការសាធារណៈទាំងអស់។ ដូច្នេះដើម្បី ងាយស្រួលក្នុងការសិក្សានោះ យើងសូមលើកយកមាត្រា ៣០ មកបង្ហាញទាំងស្រុងតែម្ដង៖

"១-អ្នករាជការសាធារណៈមានន័យថា៖

ក/បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្ដោះអាសន្នក្ដី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្ដី ដោយមិនគិតពីឋានៈអាយុ របស់បុគ្គលនោះឡើយ។

ខ/បុគ្គលឯទៀតដែលធ្វើការក្នុងមុខងារសាធារណៈរួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតមានន័យថា៖

ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំង ពលរដ្ឋ ដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដើម្បីបំពេញមុខងារសាធារណៈដទៃទៀត[10]។៉

ដូចជាមន្ត្រីនគរបាលយុត្តិធម៌ ចុះទៅធ្វើការត្រួតពិនិត្យបទល្មើស ស្រាប់តែនៅពេលដែលឃើញជនល្មើស គាត់ក៏ដេញតាមជននោះ នៅខណៈនោះជនល្មើសបានប្រព្រឹត្ត អំពើឃាតកម្មមកលើមន្ត្រីនគរបាលយុត្តិធម៌នេះ គឺគេហៅថា ៉អំពើឃាតកម្មលើអ្នករាជការសាធារណៈនៅក្នុងក្របខ័ណ្ឌនៃមុខងារ៉។ ចំណែកឯ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន គឺគាត់អត់មានមុខងារខាងហ្នឹងនោះទេ ក៏ប៉ុន្តែគាត់ទៅសហាការជួយគេ។ ដូច្នេះអ្នកដែរទៅចូលរួមសហាការជួយគេ ហើយគាត់គឺជាអ្នករាជការដែរ តែគាត់មានមុខងារគ្រាន់តែទៅចូលរួមសហាការជួយគេ ដោយមិនមែនស្ថិតនៅក្នុងក្របខណ្ឌនៃមុខងាររបស់គាត់បែបនេះ គឺគេហៅថាអ្នករាជការសាធារណៈនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

**ឧទាហរណ៍ ៖**

ដូចជាមន្ត្រីផ្សេងទៀតដែលមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ហើយគាត់ទៅជួយសហាការជាមួយមន្ត្រីនគរបាលយុត្តិធម៌ នៅពេលដែលមានអំពើឃាតកម្មលើគាត់ គឺគេហៅថា ៉អំពើឃាតកម្មលើអ្នករាជការសាធារណៈ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន៉។ អញ្ចឹងឃាតកម្មទៅលើអ្នករាជការសាធារណៈនេះ ទោះបីជានៅក្នុងក្របខ័ណ្ឌ នៃការបំពេញមុខងារក៏ដោយ ឬនៅក្នុងឱកាសនៃការបំពេញមុខងារក៏ដោយ គឺត្រូវទទួលនូវស្ថានទម្ងន់ទោសទៅតាមចំណុចទី ៤នៃមាត្រា ២០២។

សរុបមក ប្រសិនបើជាប្រព្រឹត្តអំពើឃាតកម្មទៅលើអ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃការបំពេញមុខងាររបស់គាត់ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់គាត់ គឺត្រូវទទួលនូវស្ថានទម្ងន់ទោសតាមចំណុចទី ៤ នៃមាត្រាខាងលើ។

[10] យោងតាមមាត្រា ៣០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីនិយម័យនៃអ្នករាជការសាធារណៈ: ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត

### ២.២.៤. ឃាតកម្មមានស្ថានទម្ងន់ទោសដោយគោលដៅ

ឃាតកម្មមានស្ថានទម្ងន់ទោសដោយគោលដៅ គឺត្រូវបានកំណត់ដោយក្រមព្រហ្មទណ្ឌនៃមាត្រា ២០៣ ដែលបានចែងថា៖

"ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ៣០ (សាមសិប)ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ៖

១-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឲ្យប្តឹងបរិហារពីបទល្មើស ឬសុំឲ្យធ្វើការជួសជុលព្យសនកម្ម។

២-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឲ្យជួសជុលព្យសនកម្ម។

៣-សាក្សី ដើម្បីរារាំងកុំឲ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត។

៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត[11]។"

នៅក្នុងឃាតកម្មដោយមានគោលដៅនេះ គឺគោលដៅរបស់ជនល្មើសចង់ធ្វើឃាតកម្ម ទៅលើបុគ្គលមួយចំនួនដូចខាងលើនេះ ដើម្បីបញ្ចៀសនូវការស្វែងរកយុត្តិធម៌។

#### ២.២.៤.១. ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមិនទាន់ប្តឹង

ឃាតកម្មទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឲ្យគាត់ទៅប្តឹងបរិហារពីបទល្មើស ឬកុំឲ្យទៅសុំធ្វើការជួសជុលព្យសនកម្ម។

[11] យោងតាមមាត្រា ២០៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពី បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារគោលដៅ

**ឧទាហរណ៍ ៖**

មានបទល្មើសណាមួយកើតឡើង ជនល្មើសគិតថាធ្វើយ៉ាងម៉េចកុំឲ្យជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីនេះ ទៅប្ដឹងបរិហារគាត់បាន ក៏ទៅសម្លាប់ផ្ដាច់ជីវិតជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីបំបិទដានតែម្ដង ក្នុងគោលបំណងកុំឲ្យមានអ្នកដឹងច្រើនពេក ពីព្រោះបើគាត់នៅរស់ប្រាកដជាទៅប្ដឹងហើយ អញ្ចឹងក៏ធ្វើឃាតកម្មទៅលើគាត់។ នេះគឺជាឃាតកម្មដោយមានគោលដៅ ដូច្នេះត្រូវទទួលស្ថានទម្ងន់ទោសតាមបញ្ញត្តិមាត្រា ២០៣។

### ២.២.៤.២. ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី បានប្ដឹងរួច

ឃាតកម្មទៅលើជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឲ្យជួសជុលព្យសនកម្ម មានន័យថា គឺដោយសារតែជននោះទៅប្ដឹងរួចហើយ។ ជនល្មើសអត់មានគម្រោងគិតទុកជាមុនទេ ស្រាប់តែទៅដល់ សួរថាម៉េចហើយរឿងហ្នឹងចប់គ្នាបានទេ អ្នកនោះក៏ឆ្លើយថាយើងបានប្ដឹងរួចបាត់ទៅហើយ មិនចាំបាច់ចប់គ្នាអីទេ ចាំតែទៅឆ្លើយនៅមុខតុលាការរួចសងយើងទៅបានហើយ។ គ្រាន់តែ ជនល្មើសបានឮថាប្ដឹងភ្លាមហើយ ក៏តបថាស្អីគ្រាន់តែរឿងប៉ុណ្ណឹងសម្រួលគ្នាមិនបានទេឬ? អ្នកឯងទៅប្ដឹងរួចហើយ ស្រាប់តែជនល្មើសខឹងសម្បារយ៉ាងខ្លាំងក៏ដាក់ផ្ទុសស្លាប់បាត់ទៅ។ នេះគឺឃាតកម្មទៅលើជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានប្ដឹងរួចហើយ។

### ២.២.៤.៣. សាក្សីមិនទាន់ផ្ដល់សក្ខីកម្ម

ឃាតកម្មទៅលើសាក្សី គឺដើម្បីបញ្ចៀសកុំឲ្យរកយុត្តិធម៌បាន គាត់ក៏ទៅធ្វើឃាតកម្មលើសាក្សី។ នេះគឺជាការណីអត់មានគម្រោងទេ តែប្រសិនបើមានគម្រោងគិតទុកជាមុនគឺចូលទៅក្នុងមាត្រា ២០០។ បញ្ហានេះគឺដោយសារតែគាត់ខឹងថាអ្នកដែលជាសាក្សីនោះបានដឹងរឿងច្បាស់ ម្ល៉េះហើយភ្លាមៗហ្នឹងគាត់ក៏ប្រាប់ដល់សាក្សីថាបើគេសួរអីកុំឆ្លើយឲ្យសោះ ប្រសិនតុលាការហៅអី អ្នកឯងទៅធ្វើសាក្សីឲ្យគេប្រយ័ត្នត្រូវ។ សាក្សីក៏តបថាបើគេហៅគឺត្រូវតែទៅធ្វើហើយ។ ពេលនោះជនល្មើសក៏ដាក់ផ្ទុស ឬសម្លាប់សាក្សីចោលតែម្ដងទៅដែលទង្វើនេះគឺសម្លាប់ផ្ដាច់ជីវិត ដើម្បីកុំឲ្យសាក្សីទៅផ្ដល់សក្ខីកម្មជូនដល់ស្ថាប័នមានសមត្ថកិច្ច។ នេះគឺជាឃាតកម្មដោយសារមានគោលដៅត្រូវមានស្ថានទម្ងន់ទោស។

#### ២.២.៤.៤. សាក្សីបានផ្តល់សក្ខីកម្មរួចហើយ

ឃាតកម្មទៅលើសាក្សី ដោយសារសាក្សីបានទៅផ្តល់សក្ខីកម្មរួចហើយ នៅមុខស្ថាប័នមានសមត្ថកិច្ចណាមួយដូចជានៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ឬក្នុងដំណាក់កាលនៃការស៊ើបសួរ ឬដំណាក់កាលនៃការជំនុំជម្រះ ឬក៏នៅក្នុងដំណាក់កាលនៃនីតិវិធីបណ្តឹងផ្សេងទៀត ស្រាប់តែជនល្មើសបានសម្លាប់សាក្សីនោះចោល នេះគឺជាស្ថានទម្ងន់ទោសដែរសម្រាប់មាត្រា ២០៣ ប្រសិនបើគ្មានការគិតទុកជាមុនដូចមាត្រា ២០០។

**ចំណាំ ៖**

ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមិនទាន់ប្តឹង និង ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងរួច គឺឃាតកម្មលើជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណីដូចតែគ្នាទេ។ ក៏ប៉ុន្តែវាគ្រាន់តែខុសគ្នានៅត្រង់ថា ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីអត់ទាន់បានទៅប្តឹងទេ ឯជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងរួច គឺបានទៅប្តឹងរួចរាល់ហើយ។

សាក្សីមិនទាន់ផ្តល់សក្ខីកម្ម និងសាក្សីបានផ្តល់សក្ខីកម្ម គឺមានបុគ្គលដែលជាសាក្សីដូចគ្នា ប៉ុន្តែខុសគ្នាត្រង់ថា សាក្សីមិនទាន់ផ្តល់សក្ខីកម្ម គឺសាក្សីអត់ទាន់បានទៅឆ្លើយឬទៅផ្តល់សក្ខីកម្មនោះទេ ចំណែកឯសាក្សីបានផ្តល់សក្ខីកម្ម គឺសាក្សីបានទៅផ្តល់ភស្តុតាងជូនតុលាការរួចហើយ ឬទៅផ្តល់ភស្តុតាងនៅចំពោះមុខនីតិវិធីនៃបណ្តឹងរួចហើយ ក្រោយមកជនល្មើក៏បានធ្វើឃាតកម្មទៅលើជននេះ។

### ២.២.៥. ឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ

បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ គឺជាការប្រព្រឹត្តបទល្មើសដោយអ្នករាជការសារធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន[12]។ បើយើងមើលទៅលើក្រមរបស់យើងវិញ មានចែងនៅក្នុងមាត្រា ២០៤ នៃក្រមព្រហ្មទណ្ឌ បានចែងថា៖

[12] យោងតាមមាត្រា ២០៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីបទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ

"ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ៣០ (សាមសិប)ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។"

អម្បិញមិញយើងបានឃើញឃាតកម្មទៅលើអ្នករាជការសាធារណៈនៅក្នុងមាត្រា ២០២ចំណុចទី ៤។ រីឯមាត្រា ២០៤ នេះគឺជនល្មើសជាអ្នករាជការសាធារណៈវិញម្តង ដែលនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់គាត់ ឬក្នុងឱកាសនៃការបំពេញមុខងាររបស់គាត់ ហើយគាត់បានទៅធ្វើឃាតកម្មលើអ្នកនោះ។

### ២.២.៥.១. ប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន

មន្ត្រីមួយដែលចុះទៅប្រតិបត្តិច្បាប់ ដោយសារតែក្នុងឱកាសនៃការបំពេញមុខងារនេះ ឬក៏ក្នុងក្របខ័ណ្ឌនៃមុខងាររបស់គាត់នេះ គាត់បានទៅសម្លាប់ជនណាម្នាក់ ដោយមិនចូលទៅក្នុងស្ថានភាពនៃការការពារស្របច្បាប់នោះទេ។ ប៉ុន្តែដោយសារតែ គាត់ខឹងសម្បារនឹងជនល្មើសខ្លាំងពេក ដូចជាមន្ត្រីនគរបាលយុត្តិធម៌ទៅដេញចាប់ជនល្មើស ពេលចាប់បានហើយ ជនល្មើសហាក់បីដូចជាតវ៉ាខ្លាំងពេក។ មន្ត្រីនោះក៏ថាយើងខំដេញឯងហត់សឹងស្លាប់ ហេតុអីឯងតវ៉ាច្រើនម្ល៉េះ? បន្ទាប់មកក៏សម្លាប់ជនល្មើសចោលតែម្តងទៅ បែបនេះគឺគេហៅថាឃាតកម្មដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈនៅក្នុងក្របខណ្ឌនៃមុខងារ។

### ២.២.៥.២. ប្រព្រឹត្តនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន

ផ្សេងពីនេះទៀត ប្រសិនបើមន្ត្រីរាជការដែលទៅជួយសហការបំពេញការងារ ចាប់ជនល្មើសដោយមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួនទេ តែបែរជាទៅសម្លាប់ជនល្មើសនោះ ហេតុដូច្នេះនេះ គឺជាឃាតកម្មដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។ ឃាតកម្មប្រភេទនេះត្រូវទទួលស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២០៤ គឺត្រូវជាប់ពន្ធនាគារ ឬត្រូវជាប់គុកពីចន្លោះ **១៥ (ដប់ប្រាំ)ឆ្នាំ ទៅ ៣០(សាមសិប)ឆ្នាំ**។

### ២.២.៦. ឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ

ឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ គឺជាបទល្មើសដែលកើតក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ[13]។ បើយើង មើលទៅលើក្រមរបស់យើងវិញ មានចែងនៅក្នុងមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ បានចែងថា៖

"ឃាតកម្មដែលកើតក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ **ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត**។"

#### ២.២.៦.១. ឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ

មានន័យថា នៅពេលធ្វើទារុណកម្មទៅក៏សម្លាប់ជនរងគ្រោះតែម្តង ឬក៏ក្រោយពេលដែលធ្វើទារុណកម្មហើយ ក៏សម្លាប់ចោលទៅ។ ករណីនេះគឺត្រូវទទួលស្ថានទម្ងន់តាមបញ្ញត្តិមាត្រា ២០៥ គឺ **ត្រូវដាក់ពន្ធនាគារអស់មួយជីវិត**។

#### ២.២.៦.២. ឃាតកម្មដោយមានអំពើរំលោភសេពសន្ថវៈ

ពេលរំលោភសេពសន្ថវៈរួចទៅក៏សម្លាប់ជនរងគ្រោះតែម្តង ឬមួយក្រោយពេលរំលោភហើយក៏សម្លាប់ជនរងគ្រោះចោលតែម្តងទៅ ទាំងនេះគឺជាឃាតកម្មនៅក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ។ នៅក្នុងករណីនេះដែល គឺត្រូវទទួលស្ថានទម្ងន់ទោសតាមប្បញ្ញត្តិមាត្រា ២០៥ គឺត្រូវដាក់ពន្ធនាគារអស់មួយជីវិត។

**គួរកត់សម្គាល់ ៖**

ប្រហែលជាពេលខ្លះយើងភ្លេចគិតមើលមាត្រា ២០៥។ នៅពេលដែល មានអំពើរំលោភហើយសម្លាប់ ប្រហែលជាខំទៅបើកមើលពីមាត្រា ២៣៩ ដល់មាត្រា ២៤៥ ដោយគិតថារឿងនេះគឺរំលោភហើយសម្លាប់ទៀត ដូច្នេះបើមិនបានមកគិតដល់មាត្រា ២០៥ ទេ យើងហ៊ានទៅចោទពីរមាត្រា គឺខុស

[13] យោងតាមមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីបទឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ

ស្រទ្បះតែម្តង ពីព្រោះទោសជាប់ពន្ធនាគារវាគឺស្រាលណាស់ឬខុសគ្នាឆ្ងាយណាស់។ ប្រសិនជាចោទពីបទឃាតកម្មមួយ និងចោទពីបទរំលោភសេពសន្ថវៈមួយទៀត នៅក្នុងអំពើនេះ គឺផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងច្រើនបំផុតបាន ១៥ ឆ្នាំទេ លើកលែងតែយើងរកភស្តុតាងបញ្ជាក់ថាឃាតកម្មនេះបានគិតទុកជាមុន។ ប៉ុន្តែចំពោះអំពើនេះគឺសូមចងចាំថា មាត្រា ២០៥ បានចែងយ៉ាងច្បាស់ហើយ ទោះបីជាគ្មានការគិតទុកជាមុនក៏ដោយ ឲ្យតែរំលោភហើយសម្លាប់ ឬក៏ក្នុងពេលរំលោភហ្នឹង ដោយសារតែជនរងគ្រោះប្រតាយប្រតប់ខ្លាំងពេក ជនល្មើសក៏ច្របាច់កជនរងគ្រោះឲ្យស្លាប់បាត់បង់ជីវិតទៅ។ នេះគឺជាឃាតកម្មក្នុងពេលរំលោភសេពសន្ថវៈ ឬឃាតកម្មនៅក្រោយពេលរំលោភសេពសន្ថវៈបែបនេះ ត្រូវផ្តន្ទាទោសអស់មួយជីវិតតាមប្បញ្ញត្តិមាត្រា ២០៥។

ដូច្នេះសូមកុំច្រឡំទៅចោទចំនួនពីរបទល្មើស គឺសម្លាប់ផង និងរំលោភផង ពីព្រោះបទឃាតកម្មតាមប្បញ្ញត្តិមាត្រា ១៩៩ បើអត់មានស្ថានទម្ងន់ទោសទេ គឺជាប់ពន្ធនាគារបានតែចន្លោះពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ ប៉ុណ្ណោះ និងរំលោភសេពសន្ថវៈតាមប្បញ្ញត្តិមាត្រា ២៣៩ បើអត់មានស្ថានទម្ងន់ទោសទេ គឺអាចដាក់ពន្ធនាគារចន្លោះពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំទេ។ ហេតុនេះបទល្មើសចំនួនពីរនៅក្នុងអំពើដែលយើងចោទនេះ តុលាការមិនអាចប្រកាសទោសលើសពី ១៥ឆ្នាំទេ ពីព្រោះមាត្រា ២៣៩ គឺអតិបរមានៃទោសរបស់វាស្មើ ១០ ឆ្នាំ និងមួយទៀតត្រង់មាត្រា ១៩៩ គឺអតិបរមានៃទោសរបស់វាស្មើ ១៥ ឆ្នាំ។ បើដូច្នេះ មែនតុលាការអត់មែនទៅផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ ១០ ឆ្នាំ និង បទឃាតកម្ម ១៥ ឆ្នាំ បើយើងបូកទៅ ស្មើ ២៥ ឆ្នាំ គឺខុសទៅនឹងគោលការណ៍ក្នុងបញ្ញត្តិមាត្រា ១៣៧ "ការចោទប្រកាន់តែមួយ" នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះគឺមិនអាចទៅយកបទល្មើសដែលយើងចោទចំពោះជននោះច្រើន បែរជាយើងទៅផ្តន្ទាទោសម្តងមួយៗ រួចសរុបចេញចំនួនទោសទាំងអស់ដូចនៅប្រទេសអាមេរិកនោះទេ។

## ២.៣. ទោសបន្ថែមនៃបទល្មើសឃាតកម្ម៖ ប្រភេទ និងរយៈពេល

ក្រៅពីមូលទោសដែលមានកំណត់នៅក្នុងប្បញ្ញត្តិនីមួយៗទៅតាមស្ថានទម្ងន់របស់វា គឺថាសម្រាប់បទឃាតកម្មនេះក៏មាន "ទោសបន្ថែម[14]" ដូចមានចែងនៅក្នុងមាត្រា ២០៦ គឺ៖

"ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស៖

[14] យោងតាមមាត្រា ២០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីទោសបន្ថែម: ប្រភេទ និងរយៈពេល

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំ យ៉ាងច្រើន។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការរប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំ យ៉ាងច្រើន។

៣-ការហាមឃាត់ចំពោះការស្នាក់នៅសម្រាប់រយៈពេល ១០ (ដប់)ឆ្នាំ យ៉ាងច្រើន។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរឬសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំ យ៉ាងច្រើន។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀតដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់ រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំ យ៉ាងច្រើន។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសសម្រាប់រយៈពេល ២ (ពីរ)ខែ យ៉ាងច្រើន។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់រយៈពេល ៨ (ប្រាំបី)ថ្ងៃ យ៉ាងច្រើន។”

ចំពោះគោលការណ៍នៃទោសបន្ថែមនេះ គឺទាល់តែមានចែងជាក់លាក់នៅក្នុងច្បាប់ ដូចជាករណីដែលមានចែងនៅក្នុងមាត្រា ២០៦ អញ្ចឹង។ ផ្ទុយទៅវិញ ប្រសិនបើគ្មានចែងជាក់លាក់នៅក្នុងច្បាប់បែបនេះទេ តុលាការមិនអាចនឹងឃើញទៅប្រកាសទោសបន្ថែម ដើម្បីបន្ថែមទៅលើមូលទោស (ទោសដាក់ពន្ធនាគារ និងទោសពិន័យ) បាននោះទេ។ ពីព្រោះថាក្រៅ ពីប្រកាសទោសបន្ថែម ដើម្បីបន្ថែមទៅលើមូលទោសក៏បាន ឬមួយមិនប្រកាសក៏បានដែរ លើកលែងតែច្បាប់បានចែងកំណត់ជាកាតព្វកិច្ចឲ្យប្រកាសជាដាច់ខាត ជាគម្រូ គឺប្រើភាគច្រើនចំពោះនីតិបុគ្គល។ ក៏ប៉ុន្តែមាត្រា ២០៦ នេះគេ

ប្រើថា "អាចត្រូវបានប្រកាស" ទេតើគឺអស់មានន័យថា "ត្រូវតែប្រកាស" នោះឡើយ។ ដូចនេះតុលាការអាចប្រកាសបន្ថែមទៅលើមូលទោសទៀតក៏បានដែរ។

# ជំពូកទី ២

# ការប្រកាសទោសឃាតកម្ម

## ផ្នែកទី ១. ការប្រកាសទោសឃាតកម្មចំពោះរូបវន្តបុគ្គល

ជាធម្មតាការប្រកាសទោសចំពោះរូបវន្តបុគ្គល មានបីចំណុចធំៗ គឺមូលទោស ទោសបន្ថែម និងទោសជំនួស។ ហើយនៅក្នុងក្រមព្រហ្មទណ្ឌ ក៏មានចែងយ៉ាងច្បាស់លាស់ណាស់សំរាប់ការប្រកាសទោសនីមួយៗផងដែរ។ ដូចនេះដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នោះ ខ្ញុំនិងធ្វើការបកស្រាយនៅខាងក្រោមនេះ៖

### ១.១. ការប្រកាសមូលទោស

ការប្រកាសមូលទោស គឺជាការប្រកាសនៅទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ដោយនៅក្នុងចំណុចនេះដែរ យើងនឹងធ្វើការពន្យនៅរូបវន្តបុគ្គលជានីតិជនជាមុនសិន ទើបធ្វើការបកស្រាយបន្តរទៅរូបវន្តបុគ្គលជាអនីតិជនតាមក្រោមបន្ថែមទៀត។

#### ១.១.១. ការប្រកាសមូលទោសលើរូបវន្តបុគ្គលជានីតិជន

ជាគោលការណ៍ដែលទាក់ទងជាមួយការប្រកាសអំពីមូលទោសនេះ គឺមានចែងបញ្ជាក់ជូននៅក្នុងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ដែលមូលទោសមាន ២ប្រភេទ គឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់[15]។ ដូច្នេះហើយនៅក្នុងបញ្ញត្តិនៃក្រមព្រហ្មទណ្ឌនេះ បានកំណត់ទោសដាក់ពន្ធនាគារពីប៉ុណ្ណេះទៅប៉ុណ្ណេះ និងពិន័យជាប្រាក់ពីប៉ុណ្ណេះទៅប៉ុណ្ណេះ។ មិនត្រឹមតែក្រមព្រហ្មទណ្ឌទេ ក៏អាចមានបទប្បញ្ញត្តិដទៃទៀតដែលចែងដូចគ្នា ហើយភាគច្រើនក៏មានចែងអំពីទោសដាក់ពន្ធនាគាររួចក៏ចែងអំពីទោសពិន័យជាប្រាក់ថែមទៀត។ តាមបទប្បញ្ញត្តិនៃមាត្រា ៩៧ ស្តីពីរបបនៃការប្រកាសមូលទោសនេះ គឺបានចែងកំណត់ថាប្រសិនបើបទល្មើសមួយមានចែងផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង ចៅក្រមមានសិទ្ធអំណាចក្នុងការជ្រើសរើស ដើម្បីកំណត់អំពីទោសដូចខាងក្រោមនេះ៖

[15] យោងតាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីការប្រកាសមូលទោស

- ចៅក្រមអាចប្រកាសទោសទាំងពីរចូលជាមួយគ្នា មានន័យថាទាំងទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង។
- ម្យ៉ាងវិញទៀត គឺអនុញ្ញាតឲ្យចៅក្រមប្រកាសត្រឹមតែទោសដាក់ពន្ធនាគារទេ បានន័យថា អត់ប្រកាសទោសពិន័យជាប្រាក់ទេ។
- ឯជម្រើសចុងក្រោយ គឺអនុញ្ញាតឲ្យចៅក្រមប្រកាសត្រឹមតែទោសពិន័យជាប្រាក់ទេ បានន័យថា អត់ប្រកាសទោសដាក់ពន្ធនាគារក៏បានដែរ។

### ១.១.២. ការប្រកាសមូលទោសលើរូបវន្តបុគ្គលជាអនីតិជន

អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម ១៨ឆ្នាំ។ ម្យ៉ាងទៀតអនីតិជន គឺជាជនដែលច្បាប់មិនទាន់ឲ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត ឬជាជនដែលច្បាប់កំណត់ឲ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមានកម្រិត។ សម្រាប់រូបវន្តបុគ្គលជាអនីតិជនបានន័យថា គឺជាការចែងអំពីទោសសម្រាប់តែរូបវន្តបុគ្គលជាអនីតិជនដាច់ដោយឡែកពីរូបវន្តបុគ្គលជានីតិជន។ យើងដឹងហើយថា ជាទូទៅអនីតិជន គឺជាជនដែលស្ថិតនៅក្រោមអាយុ ១៨ឆ្នាំ។ ចំពោះអនីតិជនដែលស្ថិតនៅក្រោមអាយុ ១៨ឆ្នាំ យើងចែកចេញជាពីរប្រភេទ គឺ **១.១.២.១. អនីតិជនមានអាយុក្រោម ១៤ឆ្នាំ** និង**១.១.២.២. អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ។**

#### ១.១.២.១. អនីតិជនមានអាយុក្រោម ១៤ឆ្នាំ

អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ពុំទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ បានន័យថា តុលាការ មិនអាចសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំឡើយ សូម្បីតែការចោទប្រកាន់ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ក៏គាត់មិនអាចចោទប្រកាន់ទៅលើអនីតិជនបានផងដែរ។

#### ១.១.២.២. អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

ប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ វិញ គឺច្បាប់បានទុកលទ្ធភាពឲ្យចៅក្រមធ្វើការពិនិត្យទៅលើជម្រើសនៃវិធានការពីរ ដូចខាងក្រោមនេះ៖

**វិធានការទីមួយះ**

ប្រើសិនបើអនីតិជនបានប្រព្រឹត្តព្រហ្មទណ្ឌ ថៅក្រមមិនជ្រើសរើសយកវិធានការព្រហ្មទណ្ឌក្នុងការផ្តន្ទាទោសទេ គឺថៅក្រមអាចដាក់អនីតិជននោះឲ្យស្ថិតនៅក្រោម វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ហើយលក្ខខណ្ឌនៃការប្រើប្រាស់វិធានការនីមួយៗនេះគឺត្រូវបានបានចែងបញ្ជាក់ដោយប្បញ្ញត្តិនៃមាត្រា ៤០ និងមាត្រា ៤១ នៃក្រមព្រហ្មទណ្ឌ។

**វិធានការទីពីរះ**

ប៉ុន្តែបើថៅក្រមបានពិនិត្យមើលឃើញយ៉ាងច្បាស់អំពីកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនល្មើសដែលជាអនីតិជននោះ តម្រូវឲ្យច្បាប់បើកសិទ្ធិឲ្យតុលាការក៏អាចប្រកាសអំពីទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនបានផងដែរ ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ។ ប៉ុន្តែបើសិនជាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌចំពោះអនីតិជន ដោយយោងតាមកាលៈទេសៈ ដោយយោងតាមបុគ្គលិកលក្ខណៈរបស់ជនហ្នឹង គឺតុលាការអនុវត្តសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនបាន[16]។ ដោយសារតែករណីមួយចំនួន មានស្ថានភាពនៃការប្រព្រឹត្តបទល្មើសនោះវាសាហាវឃោរឃៅខ្លាំងពេក។ ចំណែកឯ ការដាក់ទោសពន្ធនាគារ និងពិន័យជាប្រាក់ ចំពោះអនីតិជនវិញ ត្រូវបានទទួលដោយស្ថានសម្រាល់នៃមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌពោលគឺ អតិបរមានៃទោសដាក់ពន្ធនាគារគឺត្រូវបានសម្រាល់ពាក់កណ្តាល ព្រមទាំងទោសពិន័យជាប្រាក់ក៏ត្រូវបន្ថយឲ្យនៅសល់ពាក់កណ្តាល់ផងដែរ។

**ឧទាហរណ៍ះ**

អនីតិជនម្នាក់មានអាយុ ១៧ឆ្នាំ បានប្រព្រឹត្តបទឧក្រិដ្ឋមួយដ៏សាហាវ ដូចជាគាត់ចាប់រំលោភសេពសន្ថវៈរួចហើយក៏សម្លាប់នារីរងគ្រោះនោះចោលថែមទៀត។ ដូចនេះយើងមិនអាចប្រើប្រាស់វិធានការតាមដាន អបរំ ការពារ និងឧបត្ថម្ភ បានឡើយ។ អញ្ចឹងនៅក្នុងករណីនេះ ជម្រើដ៏ល្អត្រឹមត្រូវជាងគេគឺអនីតិជនត្រូវទទួលទោសព្រហ្មទណ្ឌហើយ។

[16] យោងតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពី មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ

### ១.២. ការប្រកាសទោសបន្ថែម

ការប្រកាសទោសបន្ថែម គឺជាការប្រកាសនៅទោសបន្ថែមនឹងអាចប្រកាសបានលុះត្រាតែទោសនេះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈឹម ឬបទលហុ ដែលត្រូវបានធ្វើការចោទប្រកាន់[17]។ ដោយនៅក្នុងចំណុចនេះដែរ យើងនឹងធ្វើការពន្យល់ទៅលើរូបវន្តបុគ្គលជានីតិជនជាមុនសិន ទើបធ្វើការបកស្រាយបន្តរទៅរូបវន្តបុគ្គលជាអនីតិជនតាមក្រោមបន្ថែមទៀត។

#### ១.២.១. ការប្រកាសទោសបន្ថែមលើរូបវន្តបុគ្គលជានីតិជន

ការប្រកាសទោសបន្ថែមលើរូបវន្តបុគ្គលជានីតិជន អាចអនុវត្តទោសបន្ថែមដើម្បីបន្ថែមទៅលើមូលទោស លុះត្រាតែទោសបន្ថែមនោះមានចែងយ៉ាងជាក់លាក់នៅក្នុងច្បាប់ ប៉ុន្តែបើសិនជាមិនបានចែងជាក់លាក់ទេនោះ ចៅក្រមមិនអាចប្រកាសអំពីទោសបន្ថែមដើម្បីបន្ថែមទៅលើមូលទោសឡើយ។

បើយើងក្រឡេកមើលទៅលើមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ដែលមានចែងពីទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ។ ហើយចៅក្រមអាចធ្វើការអនុវត្តទៅលើនីតិជននេះទៅលើទោសដាក់ពន្ធនាគារ និងដាក់ទោសបន្ថែមដែលមានចែងនៅក្នុងមាត្រា ១០៦ ប្រសិនបើកាលណាតុលាការមើលឃើញពីភាពចាំបាច់។ ដើម្បីអនុវត្តទោសបន្ថែម ចំពោះបទល្មើសមនុស្សឃាតដោយចេតនា ដោយយើងឃើញមានតែ ៩ ចំណុចនោះទេ។ ចៅក្រមមានសិទ្ធក្នុងការសម្រេចទោសបន្ថែមបានត្រឹមកម្រិតដែលមានត្រឹមតែ ៩ ចំណុចប៉ុណ្ណោះ មិនអាចលើកយកទាំង ១៩ ចំណុចនោះមកអនុវត្តបានឡើយ ពោលជាការអនុវត្តត្រឹមកម្រិតដែលច្បាប់បានចែងទុកជាមុនប៉ុណ្ណោះ។

#### ១.២.២. ការប្រកាសទោសបន្ថែមលើរូបវន្តបុគ្គលជាអនីតិជន

ក្រៅពីទោសបន្ថែម ដែលបានប្រកាសលើរូបវន្តបុគ្គលជានីតិជននោះ ក្រមព្រហ្មទណ្ឌបានប្បញ្ញត្តិដែល ដែរបានប្រកាសទោសបន្ថែមលើរូបវន្តបុគ្គលជាអនីតិជន[18] ដើម្បីយកទៅអនុវត្តទៅលើអនីតិជន ដែលវាមានលក្ខណៈខុសគ្នាពីទោសបន្ថែមសម្រាប់នីតិជន។ ប្រកាសទោសបន្ថែមលើ

[17] យោងតាមមាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីលក្ខខណ្ឌនៃការប្រកាសទោសបន្ថែម

[18] យោងតាមមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីទោសបន្ថែម

រូបវន្តបុគ្គលជាអនីតិជន ត្រូវបានចែកចេញជា ពីរចំណុះ គឺ **១.២.២.១. អនីតិជនមានអាយុក្រោម ១៤ឆ្នាំ** និង **១.២.២.២. អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ៖**

### ១.២.២.១. អនីតិជនមានអាយុក្រោម ១៤ឆ្នាំ

អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ដោយសារតែច្បាប់មិនបានអនុញ្ញាតឲ្យប្រកាសនូវមូលទោសទៅលើគាត់រួចទៅហើយ ដូច្នេះទោសបន្ថែមក៏ដូចគ្នាដែរ គឺមិនអាចប្រកាសទៅលើគាត់បានទេ។ ពីព្រោះថា ទោបន្ថែម គឺជាទោសបន្ថែមទៅលើមូលទោសផ្ទុយទៅវិញបើគ្មានការប្រកាសមូលទោសទេ ស្មើនឹងគ្មានការប្រកាសទោសបន្ថែមដូចគ្នាដែរ។

### ១.២.២.២. អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

កាលណាតុលាការ គ្មានជម្រើសណាមួយ ក្រៅពីសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅនោះទេ តុលាការក៏គាត់អាចសម្រេចប្រើប្រាស់នូវទោសបន្ថែមសម្រាប់អនីតិជនប្រភេទនេះដែរ។ លើសពីនេះទៅទៀត បច្ចេកទេសនៅក្នុងការប្រកាសទោសបន្ថែមនេះ ក៏ប្រើដូចនឹងវិធីសាស្ត្រក្នុងការប្រកាសទោសបន្ថែមសម្រាប់រូបវន្តបុគ្គលជានីតិជនផងដែរ។ ក៏ប៉ុន្តែខុសនៅត្រង់ថាទោសបន្ថែមដែលអាចប្រកាសសម្រាប់អនីតិជនប្រភេទនេះ បើយើងយោងតាមមាត្រា ១៦១ ស្តីពី ទោសបន្ថែម មានត្រឹមតែ ៥ ចំណុចប៉ុណ្ណោះ ដែលបានចែងនៅខាងក្រោមនេះ៖

"មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន៖

1-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

2-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

3-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

4-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

5-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។"

## ១.៣. ការប្រកាសទោសជំនួស

បន្ទាប់ពីបានធ្វើការបកស្រាយនៅទោសបន្ថែមរួច ខ្ញុំសូមធ្វើការបកស្រាយនៅទោសជំនួសម្តង ដែលយើងនិងលើកឡើងនៅពីរចំនុច គឺ **១.៣.១. ការប្រកាសទោសការងារសហាគមន៍** និង **១.៣.២. ការប្រកាសទោសស្តីបន្ទោស** យើងនិងធ្វើការបកស្រាយនៅខាងក្រោមនេះ៖

### ១.៣.១. ការប្រកាសទោសការងារសហាគមន៍

ការប្រកាសទោសការងារសហាគមន៍ ពោលវាមានលក្ខណៈពិសេសណាស់ សំរាប់ការយកទៅអនុវត្តចំពោះនីតិជន និងអនីតិជន ដូចនេះ ខ្ញុំសូមធ្វើការបកស្រាយនៅខាងក្រោមនេះ៖

#### ១.៣.១.១. ការប្រកាសទោសការងារសហាគមន៍លើនីតិជន

ទោសការងារសហាគមន៍ គឺជាទោសមួយដែលគេតម្រូវឲ្យធ្វើការងារជាប្រយោជន៍រួមមួយដោយគ្មានតម្រៃនោះទេ ក៏ប៉ុន្តែជាប្រយោជន៍សម្រាប់នីតិបុគ្គលមួយ។ ចំណែកឯមាត្រា ៧២ បានផ្តល់លក្ខខណ្ឌរួមថា កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរិមាតិចជាង ឬស្មើនឹង ៣ (បី)ឆ្នាំ តុលាការអាចប្រកាសទោសការងារសហាគមន៍បាន[19] គឺមានន័យថា លក្ខខណ្ឌនេះបើប្រើជាមួយនឹងបទល្មើសធ្ងន់ធ្ងរ ដូចជាបទល្មើសឃាតកម្មជាដើម ត្រូវបានផ្តន្ទាទោសលើសពី ៣ឆ្នាំ គឺមិនអាចប្រើទោសការងារសហាគមន៍បានឡើយ។ ក៏ប៉ុន្តែជាការបន្ថែមទៅលើលក្ខខណ្ឌមួយនេះច្បាប់ចែងថា ទោសការងារសហាគមន៍នឹងអាចប្រកាសទៅបានលុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយគាត់យល់ព្រមទទួលយកការងារសហាគមន៍នេះទៅធ្វើទៀតផងដែរ[20]។ មាត្រា ១០១ នៃក្រមព្រហ្មទណ្ឌ ត្រូវបានចែងកុំឲ្យផ្ទុយទៅនឹងអង្គការពលកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ ព្រោះបានហាមឃាត់ការងារដោយបង្ខំ។ ដូច្នេះលុះត្រាតែជនជាប់ចោទ គាត់បានទទួលយល់ព្រមដោយខ្លួនឯងនៅក្នុងពេលសវនាការ។ យើងមិនអនុវត្តនូវរបបមួយដែលហៅថារបបការងារដោយបង្ខំនោះទេ

[19] យោងតាមមាត្រា ៧២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពី និយមន័យនៃការងារសហគមន៍

[20] យោងតាមមាត្រា ១០១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពី វិធានការដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោះបីការងារសហគមន៍ គឺជាទោសក៏ដោយ ក៏ប៉ុន្តែទោសនេះគឺជាប្រភេទទោសជំនួសឲ្យមូលទោស ដោយជនជាប់ចោទអាចគេចចេញពីទោសដាក់ពន្ធនាគារបាន ប៉ុន្តែគាត់ត្រូវទៅធ្វើការងារដោយគ្មានកម្រៃ និងជាប្រយោជន៍សាធារណៈទៀតផង។ ចំណែកឯ តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវបានកំណត់អំពីថិរវេលានៃការងារ និងរយៈពេលដែលត្រូវបំពេញការងរមិនអាចលើសពី ១ឆ្នាំ បានទេ[21]។

### ១.៣.១.២. ការប្រកាសទោសការងារសហគមន៍លើអនីតិជន

ការប្រកាសទោសការងារសហគមន៍លើអនីតិជន[22] ក៏ត្រូវបានក្រមព្រហ្មទណ្ឌកំណត់ផងដែង ហើយបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌ ដើម្បីឲ្យដឹងពីភាពខុសគ្នានេះ ខ្ញុំនឹងធ្វើការបកស្រាយនៅខាងក្រោមនេះ៖

### ក. ការប្រកាសទោសការងារសហគមន៍អាយុក្រោម ១៦ឆ្នាំ

មិនត្រឹមតែមូលទោស និងទោសបន្ថែម ដែលតុលាការមិនត្រូវបានប្រកាសចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ប៉ុណ្ណឹងទេ សូម្បីតែទោសការងារសហគមន៍នេះ ក៏ក្រមព្រហ្មទណ្ឌមិនបានបើកសិទ្ធិអំណាចឲ្យចៅក្រមជំនុំជម្រះធ្វើការប្រកាសទោសប្រភេទនេះ ទៅលើអនីតិជនដែលមានអាយុមិនទាន់គ្រប់ ១៦ឆ្នាំដែរ។ កន្លែងនេះខុសគ្នាត្រង់អាយុបន្តិច ពីព្រោះកាលពីលើកមុនៗ ដែលច្បាប់កំណត់ក្នុងការប្រកាសមូលទោស និងទោសបន្ថែមទៅលើរូបវន្តបុគ្គលជាអនីតិជនគឺមានត្រឹមតែអាយុក្រោម ១៤ ប៉ុណ្ណោះ ប៉ុន្តែករណីពិសេសនេះ គឺទាល់តែអាយុក្រោម ១៦ឆ្នាំ ទើបចៅក្រមអត់មានសិទ្ធិប្រកាសទោសការងារសហគមន៍ទៅលើអនីតិជនឡើយ។

### ខ. ការប្រកាសទោសការងារសហគមន៍អាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

អនីតិជនត្រូវមានអាយុយ៉ាងតិច ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ទើបទទួលការប្រកាសទោសការងារសហគមន៍បាន ចំណែកឯថេរវេលាដែលអាចឲ្យអនីតិជននោះធ្វើការងារ មិនឲ្យលើពី ១០០ ម៉ោងទេ។ បានសេចក្តីថា ថិរវេលានៃទោសការងារសហគមន៍ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៦ ដល់

[21] យោងតាមមាត្រា ១០២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពី ថិរវេលា និងអំឡុងពេលនៃការងារសហគមន៍

[22] យោងតាមមាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីទោសការងារសហគមន៍

ក្រោម ១៨ឆ្នាំ ច្បាប់បានកំណត់ត្រឹមពាក់កណ្ដាលនៃ ២០០ ម៉ោង ស្មើ ១០០ម៉ោង។ ម្យ៉ាងវិញទៀត ត្រូវជ្រើសរើសការងារដោយសមស្របសម្រាប់អនីតិជននោះ ជាពិសេសស្ថានភាពរបស់អនីតិជនដែលទាក់ទងនឹងការបណ្ដុះបណ្ដាល និងស្ថានភាពអប់រំចំពោះអនីតិជនឲ្យចូលទៅក្នុងសង្គម។ សូមប្បីតែច្បាប់ ស្ដីពីការងារ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ១៩៩៧ ក៏មានការពាក់ព័ន្ធនឹង ការងារសម្រាប់ក្មេងដែលបានកំណត់ត្រឹមអាយុ ១៥ឆ្នាំប៉ុណ្ណោះ ពោលគឺអនីតិជនអាចធ្វើការងារកម្មករនិយោជិកបានហើយ[23]។

### ១.៣.២. ការប្រកាសទោសស្ដីបន្ទោស

ចំពោះទោសស្ដីបន្ទោសវិញម្ដង គឺការស្ដីបន្ទោសមានចែងតែមួយគត់នៅក្នុងមាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នោះ ខ្ញុំនឹងធ្វើការបែងចែក នឹងបកស្រាយចេញជាពីរចំណុច គឺ **១.៣.២.១. លក្ខខណ្ឌដើម្បីប្រកាសទោសស្ដីបន្ទោស** និង **១.៣.២.២. ការប្រកាសនូវទោសស្ដីបន្ទោសចំពោះរូបវន្តបុគ្គលទាំងពីរភេទ** នៅខាងក្រោមនេះ៖

#### ១.៣.២.១. លក្ខខណ្ឌដើម្បីប្រកាសទោសស្ដីបន្ទោស

ការណាបើជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលមានអតិបរិមាតិចជាង ឬស្មើ នឹង ៣ឆ្នាំ តុលាការអាចប្រកាសស្ដីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌ ទាំងបីដូចតទៅនេះ៖

- **លក្ខខណ្ឌទី ១៖** ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើសបានបបញ្ចប់ ពោលគឺត្រូវបានគេប្រើប្រាស់នៅពេលដែលអ្នកដែលបានប្រព្រឹត្តបទល្មើសនោះមានស្ថានភាពបទល្មើសមានលក្ខណៈមិនធ្ងន់ធ្ងរ ពិសេសគឺនៅពេលមានបទល្មើសរួចហើយមតិសាធារណៈជន ពុំសូវចាប់អារម្មណ៍ទេ ពីព្រោះថាអត់ទៅប៉ះពាល់អីខ្លាំងក្លា ដែលបណ្ដាលឲ្យប៉ះពាល់ដល់សាធារណៈតទៅទៀត។
- **លក្ខខណ្ឌទី ២៖** ការខូចខាតត្រូវបានជួសជុលរួចហើយ បានន័យថា ក្រោយពេលប្រព្រឹត្តបទល្មើសរួចហើយ ជនល្មើសបានជួសជុលនូវព្យសនកម្មរបស់ខ្លួន ឬជួសជុលការខូចខាត ដូចជាសំណងការខូចខាតទៅលើវត្ថុ ឬសំណងជម្ងឺចិត្តវិញជាដើម។
- **លក្ខខណ្ឌទី ៣៖** ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញបានសេចក្ដីថា គាត់ចងបង្ហាញពីឆន្ទៈថាគាត់មានវិប្បដិសារីមានការសោកស្ដាយចំពោះ

[23] យោងតាមមាត្រា ១៧៧ នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧

កំហុស ដែលខ្លួនបានប្រព្រឹត្តបទល្មើសនោះ នឹងធ្វើការផ្លាស់ប្តូរនៅកំហុសរបស់គាត់ ព្រមទាំងចូលខ្លួនរៀនសូត្រ អប់រំកែប្រែខ្លួនឯង ដើម្បីអាចធ្វើសមាហរណកម្មចូលទៅរួមរស់នៅក្នុងសង្គមវិញបាន។

ដូច្នេះ ប្រសិនបើចូលគ្រប់លក្ខខណ្ឌទាំងបីខាងលើនេះហើយ ចៅក្រមធ្វើការប្រកាសទោសស្តីបន្ទោសជំនួសឲ្យមូលទោសបានហើយ។ ចំណែកឯចៅក្រមដែលបានប្រកាសទោសជំនួសណាមួយហើយ ចៅក្រមនោះមិនអាចប្រកាសមូលទោសបានទេ[24]។

### ១.៣.២.២. ការប្រកាសនូវទោសស្តីបន្ទោសចំពោះរូបវន្តបុគ្គលទាំងពីរភេទ

ដោយសារតែយល់ឃើញថា ទោសដែលអាចអនុវត្តចំពោះអនីតិជនមានចែងចាប់ពីមាត្រា ១៦០ ទៅដល់មាត្រា ១៦៦ ពុំមានទោសស្តីបន្ទោសទេ ប៉ុន្តែចម្ងន់នៅក្នុងចំណុចនេះ យើងអាចដោះស្រាយបានដោយលើកយកមាត្រា ៧៦ ស្តីពី "របបគតិយុត្តនៃការស្តីបន្ទោស"។ ដើម្បីយកមកធ្វើជាទឡ្ហីករណ៍ផ្នែកគតិយុត្ត ឬអំណះអំណាងតាមផ្លូវច្បាប់បាន។ ដោយរូបវន្តជានីតិជន និងអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ គឺចៅក្រមអាចយកមាត្រា ៧៦ មកប្រកាសបានដូចគ្នា ចំពោះទោសស្តីបន្ទោសដែលចែងនៅក្នុងក្រមព្រហ្មទណ្ឌ។ ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ចុះក្រោមមិនទទួលខុសត្រូវចំពោះទោសស្តីបន្ទោសនៃក្រមព្រហ្មទណ្ឌឡើយ[25]។

## ផ្នែកទី ២. ការប្រកាសទោសព្រហ្មទណ្ឌចំពោះនីតិបុគ្គល

យើងបានដឹងហើយថា នីតិបុគ្គល ជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់សិទ្ធ និងកាតព្វកិច្ច។ ចំណុចដែរទាក់ទងពីនីតិបុគ្គលនេះ ខ្ញុំនឹងពន្យល់អំពីនីតិបុគ្គលសាធារណៈ ដូជារដ្ឋជាដើម និងនីតិបុគ្គលឯកជន ដូចជាក្រុមហ៊ុន អង្គការ សមាគម សហជីព រោងចក្រជាដើម។ ល។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នោះ ខ្ញុំសូមលើកយកពីរចំណុច គឺ **២.១. នីតិបុគ្គលនៃនីតិសាធារណៈ ឬនីតិបុគ្គលដែលជារដ្ឋ** និង**២.២. នីតិបុគ្គលនៃនីតិឯកជន ឬនីតិបុគ្គលមិនមែនជារដ្ឋ** នៅខាងក្រោមនេះ៖

---

[24] យោងតាមមាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីការប្រកាសទោសជំនួស

[25] យោងតាមមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្តីពីវិធានការអនុវត្តចំពោះអនីតិជន

### ២.១. នីតិបុគ្គលនៃនីតិសាធារណៈ ឬនីតិបុគ្គលដែលជារដ្ឋ

នីតិបុគ្គលនៃនីតិសាធារណៈ គឺជាក្រុមមនុស្សដែលច្បាប់បានអនុញ្ញាតឲ្យធ្វើសកម្មភាពដូចជាបុគ្គលដែរ ដើម្បីជាផលប្រយោជន៍សាធារណៈ។

ដោយយោងទៅតាមមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌ ស្ដីពី ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល បានចែងថា "នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀតនីតិបុគ្គល លើកលែងតែ **រដ្ឋ** ចេញអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។" ដោយយោងតាមឃ្លាខាងលើនេះ បានបញ្ជាក់ថា **រដ្ឋ** ដែលជានីតិបុគ្គលនៃនីតិសាធារណៈនេះ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ពោល **រដ្ឋ** ក៏មិនទទួលខុសត្រូវទោសព្រហ្មទណ្ឌដែរ។ ដោយសារតែក្រមព្រហ្មទណ្ឌមិនអាចចែងដើម្បីរំលាយ រដ្ឋ ឬ នគរ ឬ បុរី ឬ ប្រទេសមួយចោលបានឡើយ ដោយសារតែ **រដ្ឋ** ជាអ្នកគ្រប់គ្រងសង្គម ពោលគឺរដ្ឋ ជាអ្នកបង្កើតច្បាប់ ដើម្បីដាក់ទោសចំពោះជនណាដែលបានប្រព្រឹត្តបទល្មើស។

**ឧទាហរណ៍៖**

យោងតាមក្រមព្រហ្មទណ្ឌ ចំពោះទោសបន្ថែមដែលអនុវត្តទៅលើនីតិបុគ្គល មានចំណុចមួយដែលនិយាយពីការរំលាយនីតិបុគ្គលនោះចោល[26]។ ចុះប្រសិនបើ ប្រទេសកម្ពុជារបស់យើងវិញដែលជានីតិបុគ្គលផងដែរនោះ ត្រូវបានរំលាយចោល ពោលគឺវាប៉ះពាល់ដល់អធិបតេយ្យជាតិរបស់ព្រះរាជាណាចក្រកម្ពុជា[27] ហើយក៏ផ្ទុយពីរដ្ឋធម្មនុញ្ញផងដែល។ ចុះបើយើងនិយាយឲ្យសាមញ្ញថា ប្រសិនបើយើងអនុញ្ញាតឲ្យក្រមព្រហ្មទណ្ឌ រំលាយក្រសួងមួយចំនួនចោលវិញនោះ តើក្រសួងនោះអាចដំណើរការទៅលើវិស័យសង្គមកិច្ច ឬ វិស័យសេដ្ឋកិច្ច បានដែលឬទេ បើយើងរំលាយវាបាត់ទៅហើយនោះ។ នេះសបញ្ជាក់ឲ្យឃើញថា នីតិបុគ្គលដែលជារដ្ឋ គឺមិនអាចរំលាយចោលបានបាននោះទេ ពោលបានន័យថា មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

[26] យោងតាមមាត្រា ១៧០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ស្ដីពីការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

[27] យោតាមមាត្រា ១ ដល់មាត្រា ៦ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឆ្នាំ១៩៩៣

### ២.២. នីតិបុគ្គលនៃនីតិឯកជន ឬនីតិបុគ្គលមិនមែនជារដ្ឋ

នីតិបុគ្គលនៃនីតិឯកជន ឬពេលខ្លះយើងហៅថានីតិបុគ្គលឯកជនគឺជាក្រុមមនុស្ស ឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច និងបិតក្រោមវិធានការទាំងឡាយ ដែលគ្រប់គ្រងទំនាក់ទំនងគតិយុត្តរវាង បុគ្គលឯកជន និងបុគ្គលឯកជន ហើយមិនបិតនៅក្រោម នីតិសារធារណៈទេ[28]។ ក្រៅពី **រដ្ឋ** នីតិបុគ្គលឯកជនមានដូចជា អង្គការ ក្រុមហ៊ុន សមាគម សហជីព រោងចក្រ ។ល។ ដែលជាប្រធាននៃបទល្មើសនៅក្នុងសង្គមស៊ីវិល្បែ ឬសង្គមសម័យទំនើបនេះនាពេល បច្ចុប្បន្នត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ឬទទួលទោសព្រហ្មទណ្ឌ។

យើងបានដឹងហើយថា ទោសដែលត្រូវយកមកប្រកាសទៅលើនីតិបុគ្គល គឺមានតែ ពីរ ប្រភេទ ប៉ុណ្ណោះ ដូចជា ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស និងទោសបន្ថែមទាំង ១៥ចំណុច។ ដែល វាផ្ទុយទៅវិញ គឺពុំមានទោសជំនួសឡើយ ដោយសារតែមិនអាចឲ្យនីតិបុគ្គលដែលជាមនុស្សអរូបិយ៍ ទៅធ្វើការងារសហគមន៍ ឬក៏ស្តីបន្ទោសទៅលើមនុស្សគ្មានរូបនេះឡើយ។ រីឯចំណុចពិសេសនៅទីនេះ គឺចំពោះការប្រកាសទោសបន្ថែម ក្រមព្រហ្មទណ្ឌបានចងកាតព្វកិច្ចចំពោះចៅក្រម ឬចាប់បង្ខំឲ្យចៅ ក្រមត្រូវតែប្រកាសទោសបន្ថែមទៅលើនីតិបុគ្គល ពោលមានន័យថា ទោសបន្ថែមសម្រាប់នីតិបុគ្គល មិនមែនជាជម្រើសរបស់ចៅក្រមថាអាចប្រកាស ឬមិនប្រកាសដូចរូបវន្តបុគ្គលឡើយ។ ដូច្នេះ នៅពេល ដែលតុលាការសម្រេចផ្តន្ទាទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស ចំពោះនីតិបុគ្គលណាមួយ ហើយ តុលាការមានកាតព្វកិច្ចត្រូវតែប្រកាសនូវទោសបន្ថែមជាដាច់ខាតទៅលើនីតិបុគ្គលណាមួយ នោះ។

**ឧទាហរណ៍៖**

ដោយយោងតាមមាត្រា ៣៣៦ នៃក្រមព្រហ្មទណ្ឌ ស្តីពី ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិ បុគ្គល បានចែងថា នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែល មានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើស ដែលមានចែងក្នុងមាត្រា ៣៣០ (បទញុះញង់ឲ្យបោះបង់ទារក) មាត្រា ៣៣១ (បទអន្តរការរវាងអន្តរ

[28] សន្ទានុក្រមពាក្យច្បាប់ផ្នែករដ្ឋប្បវេណី ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ២០០៧ លេខរៀងទី៧១ និង៧៦

ការរវាងអ្នកសុំកូន និងអ្នកបោះបង់កូន) និងមាត្រា ៣៣២ (បទអន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ) នៃក្រមនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០០០០០ (មួយលាន)រៀល ទៅ ៥០០០០០០ (ប្រាំលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ៖

1-ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមដាន់របស់តុលាការ តាមបែបបទកំណត់ ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមនេះ។

2-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើនតាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ។

3-ការបិទគ្រឹស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ។

4-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

5-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ។

6-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍)នៃក្រមនេះ។

សបញ្ជាក់ឲ្យឃើញថា ទោសបន្ថែមសម្រាប់យកមកអនុវត្តទៅលើនីតិបុគ្គល ជាកាតព្វកិច្ចដែលបានចងចៅក្រមឲ្យត្រូវតែប្រកាសជាមួយមូលទោសក្នុងប្រភេទទោសពិន័យ។

# ជំពូកទី ៣

# មូលហេតុផ្សេងៗ និង

# វិធានការប្រឆាំងនឹងអំពើឃាតកម្ម

ដូចដែលបានបកស្រាយនៅខាងលើនេះ អំពើឃាតកម្ម វាបានបង្ករឲ្យមាននូវសោតនាដកម្ម និងផលវិបាកយ៉ាងធ្ងន់ធ្ងរចំពោះបុគ្គលដែលពាក់ព័ន្ធ និងសង្គមជាតិទាំងមូលទៀតផង។ គោលដៅចម្បង ដើម្បីរៀបចំសង្គមឲ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ និងសន្តិសុខល្អនៅក្នុងសង្គមត្រូវមានវិធានការ ដោះស្រាយបញ្ហានេះឲ្យមានប្រសិទ្ធភាពខ្ពស់ និងត្រឹមត្រូវបានល្អ យើងគួរធ្វើការពិនិត្យ និងវិភាគស្វែងរកមូលហេតុផ្សេងៗនៃបណ្តាលឲ្យមានអំពើឃាតកម្មនេះ។

## ផ្នែកទី ១. មូលហេតុមានអំពើឃាតកម្ម

យោងតាមការស្រាវជ្រាវរបស់ទស្សនៈវិទូសំខាន់ៗមួយចំនួនដូចជា លោក ឡាំប្រូហ្ស (Mr.LOMBROSO ) និង លោក FERRI កត្តាដែលជាមូលហេតុជំរុញឲ្យមានបទល្មើសកើតឡើង វាមានកត្តារួមផ្សំសំខាន់ ២ ធំៗ គឺ កត្តាបុគ្គល និងកត្តាក្រៅបុគ្គល។ ដូចនេះ ខ្ញុំសូមធ្វើការបកស្រាយពីរចំណុច គឺ **១.១. កត្តាក្រៅបុគ្គល** និង **១.២. កត្តាបុគ្គល** នៅខាងក្រោមនេះ ៖

### ១.១. កត្តាក្រៅបុគ្គល

ដោយយោងទៅតាមទស្សនៈវិទូរបស់លោក ទាំងពីរខាងលើនេះ។ ពួកគាត់បានកំណត់អំពីកត្តាក្រៅបុគ្គល ដែលបានធ្វើការបែងចែកចេញជាកត្តាតូចៗចំនួន ៣ ដែលនៅក្នុងនោះ មានកត្តាច្បាប់, កត្តាអប់រំ និងកត្តារួមផ្សំផ្សេងៗ។ ដើម្បីសិក្សាទៅលើកត្តាទាំងនេះឲ្យបានច្បាស់លាស់ ខ្ញុំសូមលើកយក ៣ចំនុចនៅខាងលើនេះ មកធ្វើការបកស្រាយ **គឺ ១.១.១. កត្តាច្បាប់**, **១.១.២. កត្តាអប់រំ** និង **១.១.៣. កត្តារួមផ្សំផ្សេងៗ** នៅខាងក្រោមនេះ៖

#### ១.១.១. កត្តាច្បាប់

កត្តាច្បាប់ គឺជាកត្តាមួយដែលសំខាន់ដែលមានការទាក់ទងក្នុងការប្រព្រឹត្តបទល្មើស ហើយចំពោះបទល្មើសឃាតកម្ម ក៏មានច្បាប់ចែងដែរ។ ទោះបីជាមានច្បាប់ចែងទៅលើបទល្មើសនោះ ក៏

ដោយក៏បទល្មើសនៅតែកើតមានឡើងដដែល ទាំងនេះដោយសារតែកង្វះខាតនូវការអនុវត្តន៍ទៅលើច្បាប់ដែលមានស្រាប់ ដូចនេះការអនុវត្តន៍ និងច្បាប់ ត្រូវតែដើរទន្ទឹមនឹងគ្នា ប្រសិនបើមានតែច្បាប់តែមិនមានការអនុវត្តន៍ឲ្យបានត្រឹមត្រូវនោះ គឺបទល្មើសនៅតែកើតមានឡើងដ៏ដែរ។

### ១.១.២. កត្តាអប់រំ

ប្រទេសកម្ពុជាត្រូវបានឆ្លងកាត់នូវសង្គ្រាមអស់ជាច្រើនឆ្នាំ ជាហេតុធ្វើឲ្យបាត់បង់នូវធនធានមនុស្សដ៏មានតម្លៃជាច្រើន ដូចជា និស្សិត បញ្ញាវ័ន្ត អ្នកជំនាញឯកទេស ស្ទើរតែទាំងអស់ដោយបន្សល់ទុកប្រជាពលរដ្ឋដែលជាជនមិនចេះអក្សរជាច្រើន ហើយវាក៏ជាបន្ទុកដ៏ធ្ងន់ធ្ងរមួយសំរាប់រដ្ឋាភិបាលនៅក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ ដោយសារតែកំរិត នៃការអប់រំនៅក្នុងប្រទេសមានកំរិតទាប ធ្វើឲ្យប្រទេសមានការអភិវឌ្ឍន៍យឺតបំផុត កំរិតយល់ដឹងរបស់ប្រជាពលរដ្ឋដែលបន្សល់ទុកពីសង្គ្រាម រួមទាំងការខ្វះការអប់រំធ្វើឲ្យមនុស្សបាត់បង់នូវសីលធម៌ក្នុងខ្លួន ឈានទៅដល់ការប្រព្រឹត្តបទល្មើសផ្សេងៗដូចជាការសម្លាប់ជីវិតមនុស្សជាដើម នៅពេលដែលមានទំនាស់ជាមួយគ្នាបន្តិចបន្តួចប៉ុណ្ណោះ។ បើយើងធ្វើការសង្កេតមើលទៅប្រទេសដែលជឿនលឿន ប្រជាពលរដ្ឋរបស់គេពោរពេញទៅដោយប្រជាពលរដ្ឋដែលមានចំណេះដឹង ដូច្នេះបទល្មើសពុំសូវមាននោះទេ។ ម្យ៉ាងទៀតការអប់រំនេះ គឺជាទុនមួយសំខាន់សំរាប់បណ្ដុះបណ្ដាលនូវធនធានមនុស្សដែលរស់នៅក្នុងសង្គម កុំឲ្យមានគំនិតឃោរឃៅអមនុស្សធម៌ គ្មានចំណេះដឹង ដែលជាហេតុធ្វើឲ្យពួកគេឈានទៅរកការប្រព្រឹត្តអំពើល្មើសច្បាប់ដោយគ្មានការគិតពិចារណាអ្វីទាំងអស់។ ហេតុនេះកត្តាអប់រំនេះវាមានសារៈសំខាន់បំផុត ដើម្បីកាត់បន្ថយនូវបទល្មើសផ្សេងៗកុំឲ្យកើតមានកាន់តែច្រើន ព្រមទាំងធ្វើឲ្យសង្គមមានសន្តិសុខល្អទៀតផង។

### ១.១.៣. កត្តារួមផ្សំផ្សេងៗ

ការធ្លាក់ចុះនូវសីលធម៌សង្គម និងការធ្លាក់ចុះនូវឥទ្ធិពលសាសនា ក៏ជាមូលហេតុនាំឲ្យមានបទល្មើសកើតឡើងដែរ ហើយបទល្មើសទាំងនោះមានដូចជា ការសម្លាប់ជីវិតមនុស្ស រំលោភសេពសន្ថវៈ និងលួចប្លន់ផ្សេងៗទៀត។ ចំនែកឯប្រជាជនកម្ពុជាវិញភាគច្រើនប្រកាន់យក ព្រះពុទ្ធសាសនា ដែលសាសនានេះបានអប់រំ ទូន្មាន ប្រៀនប្រដៅឲ្យមនុស្សសាងតែអំពើល្អ និងមិនត្រូវសម្លាប់នូវជីវិតរបស់មនុស្ស ឬសត្វ នោះទេ ក៏ប៉ុន្តែសព្វថ្ងៃនេះ ការប្រតិបត្តិ តាមសាសនាត្រូវបានធ្លាក់ចុះដោយសារការរីកចំរើននៃបច្ចេកវិទ្យាទំនើប ធ្វើឲ្យមនុស្សចង់មានចង់បានភ្លេចគិតពីបុណ្យ បាប គុណ ទោស ពិសេស

ការហូរចូលនូវវប្បធម៌បរទេស។ ម្យ៉ាងវិញទៀត បច្ចុប្បន្នមនុស្សភាគច្រើនធ្វើអ្វី គឺដើម្បីខ្លួនទទួលបាននូវផលប្រយោជន៍ រហូតដល់ឈានទៅធ្វើការស៊ីឈ្នួលសម្លាប់មនុស្ស លួច ប្លន់ ឬអំពើខុសច្បាប់ផ្សេងទៀតដែលនឹកស្មានមិនដល់ ហើយការប្រព្រឹត្តបទល្មើសនេះជួនការបណ្តាលមកពីជននោះ សេពនូវគ្រឿងញៀន ដែលធ្វើឲ្យបាត់បង់នូវស្មារតី សតិ រហូតដល់ហ៊ានប្រព្រឹត្តបទល្មើសផ្សេងៗ ដូចជាការសម្លាប់ជីវិតមនុស្ស លួច ដើម្បីយកប្រាក់ទៅទិញគ្រឿងញៀនជាដើម។

### ១.២. កត្តាបុគ្គល

ទាញចេញពីកត្តាសង្គម ដែលបានលើកឡើងខាងលើ ហើយធ្វើឲ្យមនុស្សមួយចំនួនក្លាយជាជនល្មើស នៅក្នុងនោះកត្តាអប់រំ សីលធម៌ ជាកត្តាមួយដែលសំខាន់បំផុតដែលអាចធ្វើឲ្យមនុស្សម្នាក់ក្លាយជាពលរដ្ឋល្អសំរាប់សង្គម ឬក៏អាចធ្វើឲ្យសង្គមបាត់បង់នូវ សន្តិភាព និងសន្តិសុខ។ ប៉ុន្តែយោងតាមការសិក្សាស្រាវជ្រាវរបស់ឧក្រិដ្ឋវិទូនៅក្នុងពិភពលោក បង្ហាញឲ្យឃើញថា បើទោះបីជាអ្នកដែលបានទទួលនូវការអប់រំខ្ពស់យ៉ាងណាក៏ដោយ ក៏គេនៅតែប្រព្រឹត្តនូវអំពើខុសច្បាប់មួយចំនួនផងដែរ ដែលធ្វើឲ្យគេសន្និដ្ឋានថាការប្រព្រឹត្តបទល្មើស មានប្រភពចេញពីបុគ្គល។ ចំពោះបទឃាតកម្មនេះពេលខ្លះកើតឡើង ដោយសារជនល្មើស និងជនរងគ្រោះនោះជាអ្នកដែលធ្លាប់មានជម្លោះនឹងគ្នា ធ្វើឲ្យមានគំនុំរហូតឈានដល់ការកាប់សម្លាប់គ្នា ហើយអ្នកខ្លះសម្លាប់ដោយមានការគិតទុកជាមុន។

ចំពោះករណីអំពើហិង្សាក្នុងគ្រួសារក៏អាចបណ្តាលឲ្យមានមនុស្សស្លាប់ផងដែរ ទាំងនេះដោយសារតែការធ្វេសប្រហែសរបស់ជនរងគ្រោះ ឬជនល្មើស។ មួយវិញទៀត អំពើហិង្សាដោយឈានដល់ការសម្លាប់នោះ អាចបណ្តាលមកពីជនល្មើសផឹកស្រាស្រវឹង និងចង់សម្លាប់ដោយគ្មានការគិតពិចារណា។ ប៉ុន្តែករណីខ្លះទៀតជនល្មើសបានយកស្រាធ្វើជាលេសដើម្បីសម្លាប់ភាគីម្ខាងទៀត ដោយគេបានធ្វើការរៀបគំរោងទុករួចជាស្រេច។ ពេលខ្លះអំពើហិង្សាក្នុងគ្រួសារ អាចឈានដល់ការសម្លាប់យ៉ាងសាហាវព្រៃផ្សៃបំផុត។ ទាំងនេះកើតឡើងដោយសារការគិតមិនបានគ្រប់ជ្រុងជ្រោយរបស់ជនល្មើស និងការចង់បានអំណាចនៅក្នុងគ្រួសារដែលជាហេតុនាំឲ្យមានបទល្មើសកើតឡើង។

ម្យ៉ាងវិញទៀតករណីលួច ក៏អាចឈានដល់ការសម្លាប់មនុស្សផងដែរ ដោយករណីនេះកើតឡើងបណ្តាលមកពីជនរងគ្រោះជាមនុស្សដែលចូលចិត្តអួតអាង និងបង្ហាញនូវទ្រព្យសម្បត្តិរបស់ខ្លួនឲ្យគេឃើញខ្លាំងពេក ឬពេលខ្លះទៀត កើតឡើងដោយសារតែជនរងគ្រោះបានស្គាល់មុខមាត់របស់ជន

ល្មើស ឬក៏គេជាមនុស្សដែលធ្លាប់ស្គាល់គ្នាពីមុនមក ឬជនរងគ្រោះបានស្រែកឲ្យគេជួយ ឬធ្វើការប្រឆាំងតបតនឹង សកម្មភាពរបស់ជនល្មើសក៏ជាហេតុបណ្តាលឲ្យជនល្មើសសម្លាប់ជនរងគ្រោះតែម្តង។ ការសម្លាប់អាចបណ្តាលមកពី កាលៈទេសៈមួយផ្សេងទៀតដែលតាមការពិតនោះជនល្មើសមិនមានបំណងក្នុងការសម្លាប់ជនរងគ្រោះនេះទេ តែវាកើតឡើងដោយសារការធ្វេសប្រហែសរបស់ជនរងគ្រោះ ឬជនល្មើស ដូចជាគ្រោះថ្នាក់ចរាចរណ៍ជាដើម ប៉ុន្តែជនល្មើសក៏មិនអាចរួចខ្លួនបានដែល គេនិងយកច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកមកអនុវត្តន៍ទៅលើជនល្មើសនោះ។

## ផ្នែកទី ២. វិធានការប្រឆាំង និងអំពើឃាតកម្ម

អំពើឃាតកម្ម ជាអំពើមួយដែលបានកើតឡើងច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅក្នុងបណ្តាលប្រទេសដទៃទៀតដែរ ហើយអំពើនេះតែងតែបណ្តាលឲ្យសង្គម អសន្តិសុខ និងមានភាពអាណាធិបតេយ្យ អាស្រ័យហេតុនេះហើយ ទើបរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ឲ្យបានខ្លាំងដោយមានការសហការជាមួយប្រជាពលរដ្ឋ ដើម្បីលប់បំបាត់ចោលនូវបទល្មើសទាំងអស់ដែលមានក្នុងសង្គម ដើម្បីការពារនូវសន្តិសុខសណ្តាប់ធ្នាប់ សង្គម សេចក្តីថ្លៃថ្នូរ និងអាយុជីវិតរបស់មនុស្សគ្រប់រូបមានន័យថាធ្វើយ៉ាងណាកុំឲ្យមានការបាត់បង់នូវអាយុជីវិតរបស់មនុស្សដោយគ្មានមូលហេតុ។ ដើម្បីការពារកុំឲ្យមានបទល្មើសកើតឡើងទៅទៀត គឺមានវិធានការពីរ ដើម្បីប្រឆាំង និងបទល្មើសទាំងនោះ ដោយធ្វើការបកស្រាយឲ្យបានច្បាស់ទៅលើពីរចំនុច គឺ **២.១. វិធានការទប់ស្កាត់** និង **២.២. វិធានការបង្ក្រាប** នៅខាងក្រោមនេះ៖

### ២.១. វិធានការទប់ស្កាត់

វិធានការទប់ស្កាត់ គឺជាវិធានការមួយដើម្បីធ្វើការទប់ស្កាត់កុំឲ្យមានបទល្មើសកើតឡើង សំដៅទៅលើការរារាំងនូវរាល់អំពើបង្កឲ្យមានមហន្តរាយ។

ដើម្បីធ្វើការទប់ស្កាត់នូវបទល្មើស កុំឲ្យមានការកើតឡើងកាន់តែច្រើន គឺត្រូវធ្វើការអប់រំឲ្យបានច្រើនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្គមឲ្យបានយល់ដឹង និងចេះធ្វើការពិចារណានូវអំពើដែលពួកគេបានប្រព្រឹត្តនោះថា ត្រឹមត្រូវ ឬមិនត្រឹមត្រូវ ដូចជាធ្វើការអប់រំនៅតាមសាលា និងតាមមូលដ្ឋានជាពិសេសគឺត្រូវធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ ការសែត និងទស្សនាវដ្តី នូវលទ្ធផលនៃការប្រព្រឹត្តអំពើនោះឲ្យប្រជាពលរដ្ឋបានយល់ដឹងកាន់តែច្បាស់។ ម្យ៉ាងវិញទៀត យើងអាចធ្វើការទប់ស្កាត់

នូវបទល្មើសទាំងនោះបានដោយធ្វើការពង្រឹងវិស័យច្បាប់ ពង្រឹងស្ថាប័នមានសមត្ថកិច្ច និងបង្កើនការអប់រំ តាមបែបសាសនា ប្រពៃណី និងវប្បធម៌ជាដើម។

### ២.១.១. ពង្រឹងវិស័យច្បាប់

ច្បាប់ គឺជាបទដ្ឋានគតិយុត្ត ដែលអនុម័តដោយសភា នីតិបញ្ញត្តិ និងប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ ឬប្រមុខរដ្ឋ ដើម្បីធានាសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខក្នុងសង្គម។

ការពង្រឹងវិស័យច្បាប់ គឺមិនមែនមានន័យត្រឹមថា ពង្រឹងច្បាប់ណាដែលចាំបាច់នោះទេ គប្បីគួរតែពង្រឹងច្បាប់ទាំងអស់ បើច្បាប់ណាមួយមានខ្វះចន្លោះ នោះនឹងធ្វើឲ្យមានបទល្មើសកើតឡើងកាន់តែច្រើន ព្រោះថាកាលណា មានអំពើល្មើសកើតឡើង ដែលមិនមានចែងក្នុងច្បាប់ គឺតុលាការពិបាកក្នុងការកាត់ក្តី ឬផ្តន្ទាទោសទៅលើជនល្មើសណាមួយ ដែលជាហេតុអាចធ្វើឲ្យជនល្មើសរួចផុតពីសំណាញ់ច្បាប់បាន។ ម្យ៉ាងវិញទៀត ច្បាប់មានតម្លាភាពលុះត្រាតែមានការអនុវត្តន៍បានត្រឹមត្រូវទៅតាមច្បាប់ដែលបានចែង ហើយដើម្បីឲ្យការអនុវត្តន៍នោះមានលក្ខណៈត្រឹមត្រូវ គឺត្រូវឲ្យមានការយល់ដឹងអំពីវិស័យច្បាប់ឲ្យបានជ្រួតជ្រាបអំពីវិស័យច្បាប់នេះ ឲ្យច្បាស់លាស់ដើម្បីងាយស្រួលក្នុងការពន្យល់ណែនាំដល់ប្រជាពលរដ្ឋទាំងអស់ឲ្យបានដឹង បានឮ និងជ្រួតជ្រាប។ ចំពោះអ្នកអនុវត្តច្បាប់វិញ គឺត្រូវមានការគោរពដោយស្មារតីទទួលខុសត្រូវខ្ពស់ដែលជាគំរូដល់ប្រជាពលរដ្ឋ គឺមានការគោរពតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម ទើបអាចធ្វើឲ្យច្បាប់មានភាពសុក្រឹតបាន។

### ២.១.២. ពង្រឹងស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់

មុននឹងពង្រឹងស្ថាប័នមានសមត្ថកិច្ច យើងត្រូវស្គាល់ឲ្យច្បាប់អំពីសិទ្ធិអំណាច និងភារកិច្ចរបស់ស្ថាប័ននោះសិន។

ស្ថាប័នមានសមត្ថកិច្ច គឺបណ្តាអង្គភាពដែលមានភារកិច្ចក្នុងការប្រតិបត្តិការយុត្តិធម៌ ដើម្បីធានាឲ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់សង្គម ពិសេសទប់ស្កាត់ និងបង្ក្រាបឲ្យទាន់ពេលវេលានូវអំពើល្មើសច្បាប់គ្រប់ប្រភេទ ដែលបំផ្លាញដល់ផលប្រយោជន៍ប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូលដែលស្ថាប័នទាំងនោះ មានដូចជា អាជ្ញាធរស្រុក ខណ្ឌ មន្ត្រីនគរបាល តុលាការខេត្ត/ក្រុង ជាដើម។ ចំនុចសំខាន់សំរាប់ដោះស្រាយនូវវិវាទទាំងឡាយនៅក្នុងសង្គម និងដើម្បីផ្តន្ទាទោសជនល្មើសទាំងអស់

ដែលបានប្រព្រឹត្តបទល្មើស។ ដូច្នេះ ដើម្បីពង្រឹងស្ថាប័នមានសមត្ថកិច្ច គឺត្រូវធ្វើការលុបបំបាត់នូវអំពើពុករលួយ និងត្រូវតែមានឯករាជ្យខាងផ្នែកតុលាការ។

## ២.១.៣. បន្ថែមការអប់រំតាមបែបសាសនា ប្រពៃណី និងវប្បធម៌

ដោយយោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ[29]។ ការអប់រំតាមបែបសាសនានេះ គឺជាការប្រសើរណាស់ ព្រោះប្រជាពលរដ្ឋខ្មែរប្រមាណជា ៩៧% (កៅសិបប្រាំពីរ ភាគរយ) ជាពុទ្ធសាសនិក ហើយមានទីវត្តអារាមជាច្រើន ដែលជាកន្លែងសំរាប់ធ្វើការគោរពបូជា។ ម្យ៉ាងវិញទៀត ទីវត្តអារាមជាទីកន្លែងសំរាប់ធ្វើការអប់រំដ៏ប្រសើរបំផុតតាំងពីយូរណាស់មកហើយ ដោយធ្វើឲ្យប្រជាពលរដ្ឋមានការយល់ដឹង ឲ្យបានទូលំទូលាយនូវទ្រឹស្តីរបស់ព្រះពុទ្ធ គឺការគោរពនូវជីវិតមនុស្ស សត្វ ឲ្យជឿលើបុណ្យ បាប ការគោរពគ្នាទៅវិញទៅម នេះគឺជាឥរិយាបទមួយដ៏ប្រពៃ ដែលជួយអប់រំយើងឲ្យទៅរកផ្លូវល្អ និងចៀសផុតពីអំពើអបាយមុខ និងអំពើអសកម្ម ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សង្គមជាពិសេស សណ្តាប់ធ្នាប់សាធារណៈ។ តាមទ្រឹស្តីនេះ គួរធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ គឺធ្វើការពង្រឹង និងពង្រីកខាងពុទ្ធចក្រដល់អ្នកដែលគោរពព្រះពុទ្ធសាលនាឲ្យពួកគេមានជំនឿពិតប្រាកដ ហើយចំពោះអ្នកដឹកនាំត្រូវផ្តល់ជាគំរូល្អដល់អ្នកដទៃ។ មិនតែប៉ុណ្ណោះ ព្រះពុទ្ធសាសនាបានអប់រំមិនឲ្យសម្លាប់ជីវិតមនុស្ស ឬសត្វជាដើម តែបើបុគ្គលណាបានប្រព្រឹត្តអំពើដែលបណ្តាលឲ្យបាត់បង់ជីវិតមនុស្សនោះ គឺបុគ្គលនោះប្រាកដជាមានបាប ក៏ដូចជាច្បាប់ផងដែរ កាលណាបើមានមនុស្សណាម្នាក់បានសម្លាប់មនុស្សម្នាក់ផ្សេងទៀតនោះជនល្មើសត្រូវទទួលទោសតាម អ្វីដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ នៅពេលដែលពុទ្ធសាសនិកជឿលើបុណ្យបាប កម្ម ផល និងធ្វើឲ្យគេមានការភ័យខ្លាចដោយពុំហ៊ានប្រព្រឹត្តអំពើអាក្រក់ គឺនាំគ្នាប្រព្រឹត្តតែអំពើល្អ។ ដូចនេះសាសនា គឺជាផ្នែកមួយដែលជួយក្នុងការអប់រំមនុស្សឲ្យដើរតាមផ្លូវល្អ អាចជួយដល់សង្គម និងធ្វើសង្គមមានការរីកចំរើន។ មិនត្រឹមតែប៉ុណ្ណោះទេ ប្រពៃណីទំនៀមទំលាប់ក៏ជាផ្នែកមួយដើម្បីជួយក្នុងការអប់រំដល់មនុស្សដែលរស់នៅក្នុងសង្គមមួយឲ្យមានចរិតស្លូតបូត សុភាពរាបសារ មានសីលធម៌ល្អ ប្រសិនបើនៅក្នុងសង្គមមួយគ្មានប្រពៃណី វប្បធម៌ នោះសង្គមពុំមានការរីកចំរើនទេ ដូចពាក្យមួយគេបានលើកឡើងថា "*វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើនថ្កាន*" ដូចនេះ ការអប់រំតាមបែបសាសនា ប្រពៃណី និងវប្បធម៌ គឺមានលក្ខណៈល្អប្រសើរណាស់ក្នុងការអប់រំដល់មនុស្សដែលរស់នៅក្នុងសង្គម។

[29] យោងតាមមាត្រា៤៣ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

### ២.១.៤. ការបង្កើតមជ្ឈមណ្ឌលអប់រំនានា

ការបង្កើតមជ្ឈមណ្ឌលអប់រំ គឺជាគំនិតមួយដ៏ប្រសើរដែលអាចជួយអប់រំ និងបណ្តុះបណ្តាលជនអនាថា ជនក្រីក្រគ្មានទីពឹង ហើយជនដែលជាប់ក្នុងពន្ធនាគារ គឺដើម្បីធ្វើឲ្យជនទាំងនោះមានវិជ្ជាជីវៈផ្ទាល់ខ្លួន ដើម្បីធ្វើការចិញ្ចឹមជីវិតរបស់ពួកគេ នៅពេលដែលពួកគេបានរួចផុតពីទោស។ ការធ្វើដូចនេះអាចកាត់បន្ថយនូវ បទល្មើសមួយចំនួន ហើយនឹងជួយដល់សង្គមមួយផ្នែក ព្រោះថាបើជនអានាថា អ្នកក្រីក្រទាំងនោះគ្មានការអប់រំ គ្មានមុខរបរដែលអាចធ្វើឲ្យពួកគេដើរប៉ោលឡៃ លួច សម្លាប់មនុស្ស ហើយថែមទាំងងាយស្រួល ដល់ជនខិលខូចធ្វើការអូសទាញដើម្បីប្រព្រឹត្តនូវអំពើខុសច្បាប់។ នៅក្នុងប្រទេសមួយដែលសំបូរទៅដោយជនអនាថា ជនគ្មានទីពឹងប្រទេសនោះតែងតែមានបទល្មើសជាញឹកញាប់ ដែលជាហេតុធ្វើឲ្យមានភាពងាយស្រួលដល់រដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេសជាតិឲ្យបានរីកចំរើន។

### ២.១.៥. ស្ថេរភាពនយោបាយ

ស្ថេរភាពនយោបាយ គឺជាបញ្ហាមួយដ៏សំខាន់ដែលរាជរដ្ឋាភិបាល គួរតែយកចិត្តទុកដាក់ទៅលើបញ្ហានេះ ព្រោះថាកាលណាមានស្ថេរភាពហើយនោះ គឺអាចឲ្យសង្គមមានការរីកចំរើនដូចបណ្តាលប្រទេសដទៃដែលអាចឲ្យប្រជាពលរដ្ឋមានការងារធ្វើ ហើយក៏ជួយកាត់បន្ថយភាពក្រីក្របានផងដែរ។ កាលណាមានការងារធ្វើហើយស្ថេរភាពនយោបាយល្អ គឺបទល្មើសអាចថយចុះមួយកំរិតដែរ។ តែផ្ទុយទៅវិញប្រសិនបើបញ្ហានយោបាយមានអស្ថេរភាពនោះ សង្គមក៏គ្មានសន្តិសុខនៅពេលនោះ ភាពច្របូកច្របល់នេះតែកើតមានឡើងឥតឈប់ឈរ ព្រោះថាអ្នកដឹកនាំមិនបានយកចិត្តទុកដាក់ឬក៏មិន ចាប់អារម្មណ៍ទៅលើបញ្ហាសន្តិសុខសង្គមនោះទេ កត្តានេះហើយដែលបណ្តាលឲ្យសង្គមកើតមានអសន្តិសុខកាន់តែខ្លាំងឡើងៗ ដូចជា អំពើកាប់សម្លាប់ អំពើចោរកម្ម អំពើកំហែងយក រំលោភសេពសន្ថវៈ កើតឡើងជាបន្តបន្ទាប់។ ដូចនេះ ដើម្បីកាន់បន្ថយបទល្មើសឲ្យអស់ពីសង្គម ក្នុងនាមជាអ្នកដឹកនាំប្រទេសជាតិត្រូវយកចិត្តទុកដាក់ចាត់វិធានការឲ្យបានច្បាស់លាស់ និងទាន់ពេលវេលាដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរក្សាស្ថេរភាពនិយោបាយសង្គមឲ្យបានល្អ។

## ២.២. វិធានការបង្ក្រាប

សកម្មភាពនយោបាយ និងសន្តិសុខសង្គមវាមានសារៈសំខាន់ណាស់សំរាប់ប្រទេសមួយទាំងមូលដើម្បីអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចំរើន ដូច្នេះរាជរដ្ឋាភិបាលត្រូវចាប់វិធានការណ៍ជាបន្ទាន់មួយ ដើម្បីបង្រ្កាបបទល្មើសឲ្យបានទាន់ពេលវេលា ព្រមទាំងរាល់សកម្មភាពអសកម្មណាដែរបានបង្កឡើងដោយពួកឧក្រិដ្ឋជនធ្វើឲ្យកើតមាននូវបទល្មើសគ្រប់ប្រភេទ និងគ្រប់រូបភាព។ ដើម្បីទប់ស្កាត់រាល់បទឧក្រិដ្ឋនានា ដើម្បីកុំឲ្យមានព្យសនកម្មដល់សង្គមតទៅមុខទៀត រាជរដ្ឋាភិបាលក៏ដូចជាអាជ្ញាធរពាក់ព័ន្ធដទៃទៀត ត្រូវចាត់វិធានការណ៍បង្ក្រាបឲ្យទាន់ពេលវេលា និងមានប្រសិទ្ធិភាពដូចជា៖

### ២.២.១. ពង្រឹងជំនាញដល់អាជ្ញាធរមានសមត្ថកិច្ច

មន្ត្រីមានសមត្ថកិច្ចភាគច្រើនចូលបំរើការងារតាមការជ្រើសរើស មិនបានត្រឹមត្រូវដោយខ្វះបច្ចេកទេស គួបផ្សំនឹងកង្វះខាត់សំភារៈ ដែលធ្វើឲ្យមន្ត្រីមានសមត្ថកិច្ចបំពេញការងារពុំសូវបានល្អ។ ប្រភពធនធានមនុស្សមានសារៈសំខាន់ណាស់សំរាប់ជូរមន្ត្រីរាជាការជាពិសេស មន្ត្រីមានសមត្ថកិច្ចតែម្តង ដើម្បីរៀបចំសណ្តាប់ធ្នាប់សាធារណៈ ហើយដើម្បីឲ្យមន្ត្រីមានសមត្ថកិច្ច មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញមុខងារតួនាទីរបស់ខ្លួនឲ្យមានប្រសិទ្ធភាពនោះ គប្បីត្រូវតែមានការបង្កើតនូវថ្នាក់សំរាប់បំពាក់បំប៉ននូវជំនាញដល់ពួកគេឲ្យបានគ្រប់គ្នា ដោយនៅក្នុងនោះ រដ្ឋត្រូវតែបណ្តុះបណ្តាលនូវជំនាញដល់មន្ត្រីមានសមត្ថកិច្ច ដើម្បីឲ្យមានជំនាញឲ្យបានគ្រប់គ្រាន់ និងមន្ទីរពិសោធន៍នានាឲ្យបានច្រើនកន្លែង ដែលអាចធ្វើឲ្យមានភាពងាយស្រួលក្នុងការស្វែងរកជនល្មើសក៏ដូចជាការធ្វើកោសវិច្ច័យ ដើម្បីរុករកជនល្មើសផងដែរ។ បច្ចុប្បន្ន បញ្ហាសម្ភារៈសំរាប់មន្ត្រីមានសមត្ថកិច្ច គឺពុំទាន់មានលក្ខណៈទំនើប និងគ្រប់គ្រាន់នៅឡើយទេ ដែលនេះជាឧបសគ្គមួយសំរាប់មន្ត្រីជំនាញ នៅពេលធ្វើកិច្ចប្រតិបត្តិការ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី គួរតែលើកទឹកចិត្តដល់ស្មារតីរបស់ពួកគាត់ឲ្យខិតខំ បំពេញមុខងារតទៅមុខទៀត ដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈក្នុងសង្គម។

### ២.២.២. ដាក់ចេញនូវផែនការបង្ក្រាបឲ្យបានម៉ត់ចត់ និងមានប្រសិទ្ធិភាព

គ្រប់មុខសញ្ញាទាំងអស់ដែលមាននៅក្នុងដីការស្វែងរកចាប់ខ្លួន ឬស្ថិតនៅក្នុងស្ថានភាពសង្ស័យថាបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយពីមុនមក សមត្ថកិច្ចត្រូវតែស្វែងរកជាបន្ទាន់ ទោះបីជាស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសបែបណាក៏ដោយ។ នៅក្នុងករណីនេះដែរត្រូវរកគ្រប់មធ្យោបាយ ដើម្បី

សម្រេចនូវគោលដៅដែលបានដាក់ចេញមក នៅពេលដែលចុះទៅធ្វើប្រតិបត្តិការត្រូវកំណត់មុខសញ្ញាឲ្យបានច្បាស់លាស់ ដើម្បីធ្វើការបង្ក្រាបឲ្យបានទាន់ពេលវេលាគ្រប់មុខសញ្ញាទាំងអស់។ ម្យ៉ាងវិញទៀត យើងត្រូវកំណត់ទិសដៅមួយចំនួនដើម្បីពង្រឹងដល់ការបង្ក្រាបបទល្មើសដល់៖

- ការិយាល័យសរុបការងារត្រូវណែនាំដល់ខេត្ត/ក្រុង បូកសរុប និងវិភាគវាយតម្លៃពីមូលហេតុដែលនាំឲ្យមានបទល្មើស និងការកើនឡើងនៃបទល្មើស និងការបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ឲ្យបានទៀងទាត់ និងទាន់ពេលវេលា។
- ការិយាល័យព្រហ្មទណ្ឌកំរិតធ្ងន់ និងស្រាលត្រូវជំរុញកិច្ចសហប្រតិបត្តិការណ៍ជាមួយបណ្តាលខេត្ត/ក្រុងដោយបន្តការស៊ើបអង្កេតស្រាវជ្រាវករណីបទឧក្រិដ្ឋ និងជំរុញការគ្រប់គ្រងមុខសញ្ញា និងការចាប់ខ្លួនតាមដីកាឲ្យបានម៉ឺងម៉ាត់បំផុត។
- ការិយាល័យសួរចម្លើយ ជំរុញការងារបូកសរុបតាមដាន និងការអនុវត្តដីកា តាមចាប់ខ្លួននៅទូទាំងប្រទេស។
- ការិយាល័យស៊ើបការណ៍ ត្រូវសហការជាមួយខេត្ត/ក្រុង ក្នុងការក្តាប់សភាពការណ៍បទល្មើស និងចំនួនមុខសញ្ញាដែលបង្កឲ្យមានបទល្មើស ហើយមួយចំនួនទៀតដែលនៅសេសសល់ ដែលបាត់រត់គេចខ្លួន ដើម្បីមានវិធានការធ្វើអន្តរាគមន៍ក្នុងការបញ្ជូនកំលាំងស៊ើបអង្កេតជាក់ស្តែង តាមចំនុចគោលដៅដែលស្មុគស្មាញ និងស្វែងរកចាប់ជនល្មើសដែលនៅសេសសល់នៅទូទាំងប្រទេស។

### ២.២.៣. លើកទឹកចិត្តដល់អាជ្ញាធរដែលសម្រេចបាននូវភារកិច្ច

ដើម្បីធ្វើឲ្យមន្ត្រីមានសមត្ថកិច្ចសម្រេចភារៈកិច្ចឲ្យកាន់តែបានល្អនោះ គឺយើងត្រូវមានការលើកទឹកចិត្តដល់មន្ត្រីដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារៈកិច្ច គឺ៖

- ផ្តល់រង្វាន់ជាទឹកប្រាក់សម្រាប់ការលើកទឹកចិត្ត
- ផ្តល់សម្ភារៈប្រើប្រាស់ផ្សេងៗ
- ផ្តល់ប័ណ្ណសរសើរ

ការធ្វើបែបនេះ គឺដើម្បីផ្តល់នូវកំលាំងចិត្តដល់មន្ត្រីដែលមានស្នាដៃ គឺក្នុងទិសដៅមួយដើម្បីជួយពង្រឹងទាំងផ្នែកស្មារតី និងកំលាំងកាយរបស់ពួកគាត់ ដែលបានខិតខំបំពេញការងារ រហូតដល់បានទទួលជោគជ័យ ឬជ័យជំនះ។

### ២.២.៤. ការចូលរួមសហការគ្នារវាងប្រជាពលរដ្ឋ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់

ដើម្បីឲ្យមានការជិតស្និតរវាងអាជ្ញាធរ និងប្រជាពលរដ្ឋ គឺអាជ្ញាធរត្រូវចុះទៅដល់ទីកន្លែង ដើម្បីពន្យល់ណែនាំដល់ប្រជាពលរដ្ឋឲ្យបានយល់ដឹង នូវអ្វីដែលអាជ្ញាធរមានបំណងឲ្យពួកគេជួយសហការណ៍ជាមួយអាជ្ញាធរ ដើម្បីឲ្យមានភាពងាយស្រួលធ្វើការងាររបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការបង្ក្រាបបទល្មើស ដែលបានកើតឡើងនៅក្នុងមូលដ្ឋានរបស់ពួកគាត់។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សា និងបានបង្ហាញអំពីបទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩ យើងឃើញថា បទឃាតកម្មតាមក្រមព្រហ្មទណ្ឌថ្មីមានធាតុផ្សំសំខាន់បីគឺ ធាតុផ្សំនីត្យានុកូល ធាតុផ្សំអត្តនោម័ត និងធាតុផ្សំសត្យានុម័ត។

ធាតុផ្សំនីត្យានុកូល សំដៅទៅលើខ្លឹមសារដែលមានកំណត់នៅក្នុងមាត្រា ១៩៩ ដល់ មាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ។ មានន័យថា អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) ដល់ មាត្រា ២០៥ (បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើ រំលោភសេពសន្ថវៈ) នៃក្រមនេះ គឺជាបទឃាតកម្ម។

ធាតុផ្សំអត្តនោម័ត សំដៅដល់ចេតនារបស់ជនល្មើសចង់ផ្តាច់យកជីវិតរបស់ជនរងគ្រោះមានន័យថាចង់ឲ្យជនរងគ្រោះស្លាប់បាត់បង់ជីវិតពីលើលោកនេះតែម្តង។ យើងអាចបន្ថែម ទៀតថា ធាតុផ្សំអត្តនោម័តនៃអំពើមនុស្សឃាតដោយចេតនា គឺសំដៅលើចេតនារបស់ចារី នៃបទល្មើសក្នុងការផ្តល់សេចក្តីស្លាប់ដល់ជនរងគ្រោះ។ ធាតុចេតនាសម្លាប់មនុស្សនេះ គឺជាធាតុសំខាន់បំផុតដែលអាចឲ្យគេធ្វើការបែងចែកអំពើមនុស្សឃាតដោយចេតនា ចេញពីបទល្មើសផ្សេងៗទៀតដែលអាចបណ្តាលឲ្យមានលទ្ធផលដូចគ្នា គឺការបាត់បង់ជីវិតមនុស្សដូចគ្នាដែលវាដូចជាអំពើមនុស្សឃាតដោយអចេតនាជាដើម។

ធាតុសត្យានុម័តរបស់បទឃាតកម្ម ជាទង្វើសម្លាប់មនុស្សឃាតដោយចេតនា ឬជាប្រភេទបទល្មើសសកម្ម ដូចនេះអំពើសម្ភារៈនៃបទល្មើសនេះ ត្រូវស្តែងឡើងក្រោមរូបភាពជាអំពើសម្ភារៈជាវិជ្ជមាន។ និយាយម្យ៉ាងទៀត អំពើសម្លាប់មនុស្សនេះត្រូវស្តែងឡើងជាកាយវិការបង្ហាញមកខាងក្រៅ តាមរយៈអំពើជាសម្ភារៈមួយឬច្រើន។ អំពើសម្ភារៈនេះ អាចស្តែងឡើងតាមគ្រប់មធ្យោបាយទាំងអស់ដូចជាការវាយរហូតដល់ស្លាប់ ការសម្លាប់ ដោយបំពុល ដោយការប្រើប្រាស់អាវុធ ដោយការប្រើខ្សែរិតក ដោយឆក់នឹងចរន្តអគ្គិសនី ឬដោយប្រើប្រាស់រថយន្តជាដើម។

ទោសដែលត្រូវរងនៃបទឃាតកម្ម មានពីរ គឺករណីគ្មានស្ថានទម្ងន់ទោស និងករណីមានស្ថានទម្ងន់ទោស។ ករណីគ្មានស្ថានទម្ងន់ទោស គឺត្រូវទទួលទោសទៅតាមបញ្ញត្តិមាត្រា ១៩៩ គឺដាក់ពន្ធនាគារពី **១០ (ដប់)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ**។ ករណីមានស្ថានទម្ងន់ទោស មានដូចជា បទឃាតកម្មគិតទុកជាមុន និងឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់**ពន្ធនាគារអស់មួយជីវិត**។ ចំណែកឯ បទឃាតកម្មដោយប្រើថ្នាំពុល និងបទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១៥ (ដប់ប្រាំ)ឆ្នាំ ដល់ ៣០ (សាមសិប)ឆ្នាំ**។ រីឯបទឃាតកម្មដែលមានស្ថានទម្ងន់ទោស ដោយសារគោលដៅ និងបទឃាតកម្មប្រព្រឹត្តដោយអ្នករជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១៥ (ដប់ប្រាំ)ឆ្នាំ ដល់ ៣០ (សាមសិប)ឆ្នាំ**។

ម្យ៉ាងវិញទៀត អំពើឃាតកម្ម ធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំង ដែលបណ្តាល់ឲ្យសង្គមអសន្តិសុខ និងមានភាពអាណាធិបតេយ្យ អាស្រ័យហេតុនេះរដ្ឋាភិបាលគួតែយកចិត្តទុកដាក់ឲ្យបានម៉ត់ចត់ ដើម្បីការពារនូវសន្តិសុខសណ្តាប់ធ្នាប់ សង្គម សេចក្តីថ្លៃថ្នូរ និងអាយុជីវិតរបស់មនុស្សគ្រប់រូប។ ចំនែកឯមន្ត្រីវិញត្រូវធ្វើការទប់ស្កាត់នូវបទល្មើស និងធ្វើការអប់រំឲ្យបានច្រើនដល់ប្រជាពលរដ្ឋដើម្បីឲ្យប្រជាពលរដ្ឋបានយល់ដឹង និងចេះធ្វើការពិចារណានូវអំពើរបស់ខ្លួន។ ពង្រឹងនៅការផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ ការសែត និងទស្សនាវដ្តីឲ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់។ ព្រមទាំងពង្រឹងស្ថាប័នមានសមត្ថកិច្ច និងពង្រឹងវិស័យច្បាប់ឲ្យបានច្បាស់សំរាប់យកទៅអនុវត្តន៍ឲ្យត្រូវនិងគោលការណ៍ច្បាប់។ ប្រសិនបើមានច្បាប់ណាដែលមានការខ្វះចន្លោះ នោះនឹងធ្វើឲ្យមានបទល្មើសកើតឡើងកាន់តែច្រើន ពីព្រោះថាកាលណាមានអំពើល្មើសកើតឡើង ដែលមិនមានចែងក្នុងច្បាប់ គឺតុលាការពិបាកក្នុងការកាត់ក្តី ឬផ្តន្ទាទោសទៅលើជនល្មើសណាស់ ដែលជាហេតុធ្វើឲ្យរួចផុតពីសំណាញ់ច្បាប់បាន។ វិស័យច្បាប់ក៏មានសារសំខាន់ រីឯការអប់រំតាមបែបសាសនា ប្រពៃណី និងវប្បធម៌ក៏មានលក្ខណៈសំខាន់ផងដែល ដោយសារតែប្រទេសរបស់យើងប្រជាពលរដ្ឋភាគច្រើនកាន់យកព្រះពុទ្ធសាសនា ហើយច្បាប់កំពូលនៃប្រទេសកម្ពុជា គឺរដ្ឋធម្មនុញ្ញ ក៏មានចែងនៅក្នុង មាត្រា ៤៣ បានចែងថា "**ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ**"។ ការបញ្ចូលការអប់រំតាមបែបសាសនា នេះក៏ជាហេតុកាត់បន្ថយនៅការកកើតនូវបទល្មើសបានដែរ ដូចជាការអប់រំយើងឲ្យទៅរកផ្លូវល្អ និងចៀស

ផុតពីអំពើអបាយមុខ អំពើអសកម្ម ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សង្គមជាពិសេសសណ្ដាប់ធ្នាប់សាធារណៈ។

សរុបមក ក្រមព្រហ្មទណ្ឌថ្មី បានចែងយ៉ាងច្បាស់លាស់នៅបទល្មើសឃាតកម្មដែលមានលក្ខណៈងាយស្រួលក្នុងការអនុវត្តន៍ ចំពោះមន្ត្រីមានសមត្ថកិច្ចទៅលើជនទាំងឡាយណាដែលបានប្រព្រឹត្តនៅអំពើនេះ ហើយក្រមព្រហ្មទណ្ឌថ្មីបានកាត់បន្ថយនៅភាពខ្វះចន្លោះ ដែលជាមូលហេតុនាំឲ្យមានការទទួលខុសត្រូវចំពោះមុខច្បាប់ និងសង្គមជាតិ។

# អនុសាសន៍

ഌ෴📖෴ഌ

ក្នុងនាមខ្ញុំបាទជាអ្នកស្រាវជ្រាវ បញ្ចាក់ថ្នាក់បរិញ្ញាបត្រច្បាប់មួយរូប យល់ឃើញថាដើម្បីបង្ការបទល្មើសឃាតកម្ម និងការផ្តល់យុត្តិធម៌ដល់ជនល្មើស និងជនរងគ្រោះ ក៏ដូចជាការធានាការអនុវត្តក្រមព្រហ្មទណ្ឌថ្មីនេះឲ្យមានប្រសិទ្ធភាព រដ្ឋគួរតែពង្រឹងកត្តាមួយចំនួនដូចខាងក្រោមនេះ៖

- ត្រូវបន្ត និងបង្កើនការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌថ្មីឲ្យបានទូលំទូលាយ ដល់មជ្ឈដ្ឋានទូទៅនិងទូទាំងប្រទេស។
- ជ្រើសរើសមន្ត្រីតុលាការដែលមានសមត្ថភាពពិតប្រាកដ និងឲ្យបានគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែង។
- ត្រូវពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈតាមរយៈការឃ្លាំមើល និងដាក់ពិន័យរាល់ការបំពានក្រមសីលធម៌ដលចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ឬមេធាវីអគតិ។
- ត្រូវផ្តល់ប្រាក់បៀវត្សរ៍ឲ្យបានសមរម្យតាមឋានៈ និងការបណ្តុះបណ្តាលដែលធានានូវការចំណាយឲ្យកាន់តែអាចទទួលយកបាន។
- ត្រូវគោរពគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន ជាពិសេសត្រូវយកចិត្តទុកដាក់លើការគោរពសិទ្ធទទួលបានការជមនុំជម្រះតាមបែបយុត្តិធម៌ថ្នាក់ជាតិ និងអន្តរជាតិ។
- គួរបង្កើតច្បាប់ពិសេស និងសិទ្ធិអំណាចឯករាជ្យមួយ ហើយត្រូវជ្រើសរើសមនុស្សមួយក្រុមដែលមានចំណេះដឹង និងគុណធម៌ខ្ពស់ឲ្យមកកាត់ទោសដល់ចៅក្រមពុករលួយបើធ្ងន់ធ្ងរខ្លាំងពេកគឺ ដកចេញពីមុខតំណែង និងដកចេញពីពិភពអ្នកច្បាប់ទាំងនីតិប្រតិបត្តិ និងអំណាចតុលាការ មានគំរូដូចជាព្រះរាជអាជ្ញាខេត្ត ពោធ៍សាត់ គុប ចាន់សេរីវុធ និងចៅក្រមខេត្ត កណ្តាល ក៏ដូចជាក្រឡាបញ្ជីខេត្ត កណ្តាលឈ្មោះ លឹម កុម្ភៈ ផងដែរ។

# ឯកសារពិគ្រោះ

ᦸᦸ📖ᦸᦸ

## អត្ថបទច្បាប់

- ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២
- ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២
- ច្បាប់ស្តីពីការងារ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ១៩៩៧
- សេចក្តីថ្លែងការជាសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

## សៀវភៅទ្រឹស្តី

- សន្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ២០១១ លេខរៀងទី ៦៨។
- វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧។